ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៣ លេខ៦២៩ ត្រីមាសទី០២ ឆ្នាំ២០២៣

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារធាតុ

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២២៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ថាវ ហ្គួរជីន** (TAO GUOJUN) ជនជាតិ ST.KITTS AND NEVIS សញ្ជាតិ ST.KITTS AND NEVIS ដោយប្តូរឈ្មោះជា **តាំង គីមហេង** (TANG KIMHENG) | ៣៥១៥ |
| ២-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២២៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **សៀ ក័ងហ័ង** (XIE. GUANGHUANG) ជនជាតិចិន សញ្ជាតិចិន | ៣៥១៦ |
| ២-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២២៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឡ សេន** (LAW SAN) ជនជាតិមីយ៉ាន់ម៉ា សញ្ជាតិមីយ៉ាន់ម៉ា | ៣៥១៧ |
| ២-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ លោកជំទាវ **យូ អយ** | ៣៥១៨ |
| ២-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣១ ស្តីពី ការនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងយុត្តិធម៌ តាមអតីតភាពការងារ និង កម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការ ៩រូប | ៣៥១៩ |
| ២-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ប្រគេន-ជូន ព្រះសង្ឃ មន្ត្រីរាជការ និងសប្បុរសជន ១៩៧ អង្គ/រូប | ៣៥២១ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៣ ស្តីពី ការតម្លើងឋានៈឯកឧត្តម **ឈឹម សារ៉េត** ទីប្រឹក្សា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មាន ឋានៈស្មើ ទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន | ៣៥២៥ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាជំនួយការសម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៣រូប | ៣៥២៦ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៥ ស្តីពី ការតម្លើងឋានៈសមាជិកក្រុមលេខាសម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ២រូប | ៣៥២៧ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈលោកជំទាវ **ទូច សុធារត្ន** ជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន | ៣៥២៨ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៧ ស្តីពី ការតែងតាំងមុខតំណែងជា អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន ២រូប | ៣៥២៩ |

| | | |
|---|---|---|
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៨ ស្ដីពី ការតែងតាំងមុខតំណែង និងផ្ដល់ឋានៈ ឯកឧត្ដម ឧត្ដមសេនីយ៍ត្រី **ម៉ាត្រ សុត្រ** ជាអនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ មានឋានៈ និងបុព្វសិទ្ធិស្មើ អគ្គនាយក | ៣៥៣០ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៣៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឡូឆារើនវ៉ាថាណាឆៃ ចំរ៉ុង** (LOCHAREONVATHANA CHAI BAMRUNG) ជនជាតិថៃ សញ្ជាតិថៃ | ៣៥៣១ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៤០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្ដម **ថន អ៊ីម** | ៣៥៣២ |
| ៣-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៤១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ៥រូប | ៣៥៣៣ |
| ៤-២-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០២២៣/២៤៣ ស្ដីពី ការផ្ដល់គោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ៩រូប | ៣៥៣៤ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ៧-៣-២០២៣ | -អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្ដីពី ការបង្កើតមន្ទីរពេទ្យជាតិ តេជោសន្តិភាព ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល | ៣៥៣៦ |
| ២-៣-២០២៣ | -អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្ដីពី ការផ្ទេរយោធិនពិការ | ៣៥៥៤ |
| ២-៣-២០២៣ | -អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្ដីពី ការផ្ទេរយោធិនពលី | ៣៥៥៩ |
| ៣-៣-២០២៣ | -អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ៣៥៦២ |
| ៣-៣-២០២៣ | -អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែង នាយទាហាន | ៣៥៦៣ |
| ៣-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែង នាយទាហាន | ៣៥៦៤ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ៣៥៦៥ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ៣៥៧៥ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ៣៥៧៧ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៧ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ៣៥៨៥ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៣៥៨៦ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ៣៥៨៧ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្ដីពី ការលុបឈ្មោះ នាយទាហាន | ៣៥៨៨ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ | ៣៥៨៩ |
| ៦-៣-២០២៣ | -អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៣៥៩០ |

៦-៣-២០២៣ -អនុក្រឹត្យលេខ ២៥៣ អនក្រ.គត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣៥៩២

## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៧-៣-២០២២ -សារាចរលេខ ០០៣ សហវ ស្ដីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី៣ ៣៥៩៤

១៣-៣-២០២៣ -ប្រកាសលេខ ១៥១ សហវ.ប្រក.អលស ស្ដីពី ការអនុវត្តកិច្ចព្រមព្រៀងសាជីកម្មសម្រាប់មុខចំណាយជួលទីតាំងរៀបចំវគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត សម្រាប់រដ្ឋបាលថ្នាក់ជាតិ ៣៥៩៦

### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

៤-១-២០២៣ -ប្រកាសលេខ ០០១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន លានហ្វា ហេងយូ (ខេមបូឌា) ហ្គាមិន បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ៣៦១៧

៤-១-២០២៣ -ប្រកាសលេខ ០០២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ត្រីប៉ូស អ៊ិនធើណេ-សិនណល ឯ.ក បង្កើតរោងចក្រ ផលិតស្បែកជើង ៣៦២០

### ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

១៣-៤-២០២២ -ប្រកាសលេខ ០២៤០ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០២៤០ រថ.អប្រក.លអ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ៣៦២៣

២៥-៤-២០២២ -ប្រកាសលេខ ០២៤៣ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០២៤៣ រថ.អប្រក.លអ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ៣៦២៧

២៥-៤-២០២២ -ប្រកាសលេខ ០២៤៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០២៤៤ រថ.អប្រក.លអ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ៣៦៣១

២៥-៤-២០២២ -ប្រកាសលេខ ០២៤៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០២៤៥ រថ.អប្រក.លអ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ៣៦៣៥

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/៤២៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ថាវ ហ្គួជីន** (TAO GUOJUN) ជនជាតិ ST. KITTS AND NEVIS សញ្ជាតិ ST. KITTS AND NEVIS កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៨៣ នៅរដ្ឋធានី Basseterre ប្រទេស Saint Christopher ( St. Kitts ) and Nevis ដោយប្តូរឈ្មោះជា **តាំង គីមហេង** (TANG KIMHENG)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣៧៧. ២៣០២ - ៤២៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/[illegible]

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយបែសញ្ជាតូបនីយកម្មដល់លោក **សៀ គ័ងហ័ង** (XIE. GUANGHUANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩០ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២២៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឡ សេន** (LAW SAN) ជនជាតិមីយ៉ាន់ម៉ា សញ្ជាតិមីយ៉ាន់ម៉ា កើតថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៨ នៅតំបន់ Laukking សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព.រ.ល. ២៣០២.២២៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២៧០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

លោកជំទាវ **យូ អយ**

៧៧៣.២៧០២.២៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** និយ័តកម្មដំឡើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌ តាមអតីតភាពការងារ និងកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការ ០៩ រូបៈ

| | | |
|---|---|---|
| ១-លោក **អ៊ី រិទ្ធ** | ពីនាយក្រមការ ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២-លោក **អេង សុគន្ធា** | ពីនាយក្រមការ ថ្នាក់លេខ ៣ | មកជាវរមន្ត្រី ថ្នាក់លេខ ១ |
| ៣-លោក **ណុប សុផល** | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៧ | មកជាវរមន្ត្រី ថ្នាក់លេខ ១ |
| ៤-លោកស្រី **អ៊ុន ចិន្តា** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ២ | មកជាអនុមន្ត្រី ថ្នាក់លេខ ១ |
| ៥-លោក **ប្រាក់ សំណាង** | ពីក្រមការ ថ្នាក់លេខ ៤ | មកជាអនុមន្ត្រី ថ្នាក់លេខ ៤ |
| ៦-លោក **ឃឹម តុងខួង** | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ | មកជាអនុមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧-លោកស្រី **លឹម សុលីដា** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ មកជាអនុមន្ត្រី ថ្នាក់លេខ ៤
៨-លោក **តូច ចិន្តា** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ មកជាអនុមន្ត្រី ថ្នាក់លេខ ៤
៩-លោក **ឆា សុផានិត** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣៧៣ រ.ក ០២ . ២៧៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/ ២៣២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេន-ជូន ព្រះសង្ឃ មន្ត្រីរាជការ និងសប្បុរសជន ១៩៧ អង្គ/រូប៖

**ក**- គ្រឿងឥស្សរិយយស **ជាតូបការ**

១-ព្រះតេជគុណ ប៊ុន ណេង
២-ព្រះបិដកធម្ម ម៉ៅ នីម
៣-លោកជំទាវ ចាន់ សុជា សុខ ហេង
៤-ឧកញ៉ាវេជ្ជបណ្ឌិត **លិ គឹមហ៊ួរ**
៥-លោកជំទាវ ប្រាជ្ញ ពៅ លូ គឹមឈន់
៦-ឧកញ៉ា **លឹម ប៊ុន**
៧-បណ្ឌិត ជួន សារ៉ា
៨-មហាឧបាសិកា ព្រំ ធារី

**ខ**-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ព្រះតេជគុណ ហ្វាន់ ហឿន
២-ព្រះធម្មានុលក្ខណ៍ សេង ម៉េងលក្ខ័ណ
៣-ឯកឧត្តម **ឃី សម្បត្តិ**
៤-ឯកឧត្តម សុង សុមនោ
៥-លោកជំទាវ **ឃឹម ច័ន្ទម៉ូលីកា**
៦-លោក ហាង សុផាត
៧-លោក ព ឈន
៨-លោក តី វិសាល
៩-លោក ហាក់ សុខនី
១០-លោក ហ៊ត់ សីហា
១១-លោក សាយ កក្កដា
១២-លោកស្រី សុខ ស៊ីថា
១៣-លោក ឌឹម វរៈ
១៤-លោក លឹម វិចិត្រ
១៥-លោក ភួង រតនៈ
១៦-លោក ឃឹម បូរាណ
១៧-លោកស្រី យ៉ុង សុជាតា
១៨-លោក សុខ ជា
១៩-លោក គឹម សុចិត្រ
២០-លោកស្រី សួន ទេវី
២១-លោក ឃឹម សែនឧត្តម្ភ
២២-លោក ប៊ឹង សុខា
២៣-លោក ចន្ថា ភក្ត្រា
២៤-លោក ប៉ែន កុសល
២៥-លោក ផៃ កុសល
២៦-លោក ហង្ស អន
២៧-លោក ជុំ សុភ័ណ្ឌ
២៨-លោក សេង សុផាន់ណា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២៩-លោក កែវ មុន្នីរាជ
៣០-លោក អឹង សំអាង
៣១-លោកស្រី វុទ្ធី រតន៍ កន្និកា
៣២-លោក ជួប សីហា
៣៣-លោក គឹម សុភក្តិ
៣៤-លោក ម៉ែន សុផាត
៣៥-លោក គឹម កល្យាណ
៣៦-លោក កែវ សុភិវឌ្ឍន៍
៣៧-លោក ឆុង វាសនា
៣៨-លោក កោះ និច្ច
៣៩-លោក តាន់ រតនា
៤០-លោក សំរិទ្ធ កុសល
៤១-លោក អ៊ឹង ធាសុវណ្ណារិទ្ធ
៤២-លោក រិត មយៈ
៤៣-លោក តុង តុលា
៤៤-លោក ស៊ី រ៉ាណូ
៤៥-លោក ប៉ុក បញ្ញាធិ
៤៦-លោក គី គុយតេក
៤៧-លោក លី ចាន់ធា
៤៨-លោក ឃុិល យ៉ាហ្យាគី
៤៩-លោក ស្រេង វិបុល
៥០-លោក ស៊ុក ធិកា
៥១-លោក ទេព ភារក្ស
៥២-លោក ប៉េង ចាន់ណារិទ្ធ
៥៣-លោក ឡុង ឆាយ
៥៤-លោក តាំង សេរីវឌ្ឍនា
៥៥-លោក ឈឿត សុភ័ព្ទ
៥៦-លោក គីម ថៃស័រ
៥៧-លោក ហេង សីហា
៥៨-លោក មាស ពិសិទ្ធ
៥៩-លោក ស៊ូ ច័ន្ទរិទ្ធិ
៦០-លោក ឈួន សុធារិទ្ធ
៦១-លោក ហៀង ឡុងឌី
៦២-លោក លឹម ថេង
៦៣-លោក ស៊្រុន ស្រុង
៦៤-លោក ប៉ែន តុលា
៦៥-លោក ទឹម ស៊ុនតេង
៦៦-លោក ឆូវ មិនា
៦៧-លោក ស៊ិន គារី
៦៨-លោកស្រី សំ គង់
៦៩-លោក ស៊ុំ សុវណ្ណារ៉ូ
៧០-លោក ឈឿន វុទ្ធី
៧១-លោក វុធ ប៊ុនស៊ីង
៧២-លោក ឃឿន សុជាតិ
៧៣-លោក ហ៊ឹម សំណាង
៧៤-លោក ដេដ្ឋា ម៉ានិត
៧៥-បណ្ឌិត យ៉ាង សុវិជ្ជា
៧៦-លោក លី សុដារីដ្ឋ
៧៧-បណ្ឌិត ជា ជំនិត
៧៨-លោក សំ ណាត
៧៩-លោក ខឹម ចាន់នឿន
៨០-លោក ភី កានិត
៨១-លោក ម៉ោ អេងជី
៨២-លោក ជា មករា
៨៣-លោក ម៉ៅ ប៊ុនថន
៨៤-លោក ហេង ច័ន្ទឌី
៨៥-លោកស្រី មិន ខេន
៨៦-លោក កែវ ប៊ុនជី
៨៧-លោកស្រី សុន ឌីណា
៨៨-លោកស្រី ឃៀម សុមីន
៨៩-លោកស្រី ឃៀម ខេមា
៩០-លោក សន រិទ្ធា
៩១-លោក សួស គិមហ៊ាង
៩២-លោក លី គង្គា
៩៣-លោក យ៉េន រក្សា
៩៤-លោក សែត ស៊ីហ្គិច
៩៥-លោក លី បញ្ញា
៩៦-លោក ផុន ធារិន
៩៧-លោក ធៀង មិន
៩៨-លោក ឈាង សុផាន់ណា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | |
|---|---|
| ៩៩-លោក ម៉ក់ សាយ៉ែល | ១០០-លោក អ៊ិន សុធា |
| ១០១-លោក ពេជ្រ សារ៉ា | ១០២-លោក ឡាក់ សុខលី |
| ១០៣-លោក ទូច សារិន | ១០៤-លោក ឆាយ សាម៉ន |
| ១០៥-លោក សួស រិទ្ធី | ១០៦-លោក គីម គូលេន |
| ១០៧-លោក ចិន្តា តុលា | ១០៨-លោក សៀង ប៊ុនធឿន |

គ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | |
|---|---|
| ១-ឯកឧត្តម ឆេង សុភ័ក្រ | ២-លោកជំទាវ គីវ ចាន់សោភា |
| ៣-លោកវេជ្ជបណ្ឌិត សេង ណុង | ៤-លោក ចន្ទី ពិល្ |
| ៥-លោកស្រី អ៊ុំ ស៊ីវ៉ាន់ថា | ៦-លោក ចាង បាទី |
| ៧-លោក ស៊ុន ដេត | ៨-លោក ហោ សូលីដា |

ឃ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | |
|---|---|
| ១-លោកជំទាវ ឡឹក លក្ខិណា | ២-ឧកញ៉ា លឹម លីឆាយ |
| ៣-ឧកញ៉ា តាន់ តាត់ | ៤-ឧកញ៉ា គិត ប៊ុន |
| ៥-ឧកញ៉ា ស៊ុន រី | ៦-លោក ភីពិសិដ្ឋ សមរិទ្ធពង្ស |
| ៧-លោក ប៉ែន សុធា | ៨-លោក មុំ សុជាតិ |
| ៩-លោក ខេមរា តារាឫទ្ធិ | ១០-លោក ជា សម្បត្តិ |
| ១១-លោក សៀ ពិសិដ្ឋ | ១២-លោក ហាវ ហេង |
| ១៣-លោក អ៊ឹង វាសនា | ១៤-លោក ម៉ឹង សូជាឫទ្ធិ |
| ១៥-លោក សំ ករុណា | ១៦-លោកស្រី អ៊ុក មឿន |
| ១៧-លោក រ័ត្ន សិលា | ១៨-លោក ចាន់ ថេរា |
| ១៩-លោក ធុច ស៊ីថា | ២០-លោក តាក ចន្ទបញ្ញា |
| ២១-លោក មិន ម៉ូន | ២២-លោក តាក ចន្ទបញ្ញាវ័ន្ត |
| ២៣-លោក កៅ ម៉ៅ | ២៤-លោក មុំ តារា |
| ២៥-លោក ស៊ុំ យន | |

ង- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | |
|---|---|
| ១-ព្រះតេជគុណ ផុន ភារិទ្ធ | ២-លោក ឡេង អ៊ិច |
| ៣-លោកស្រី លៀង ស៊ុយហ្វ៊រ | ៤-លោកស្រី សែន សុវឌ្ឍនា |
| ៥-លោក សោម សុធារ៉ា | ៦-ឧបាសិកា ម៉ៃ យឿន |
| ៧-លោក សៃ ហួត | ៨-លោក ហុង ឆេងហ៊ួត |
| ៩-លោក ខាត់ សេងលី | ១០-លោក លី ម៉េងឆាយ |
| ១១-លោកស្រី ជួង ស៊ីជឿន | ១២-លោក ព្រុំ ចាន់នី |

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | |
|---|---|
| ១-ព្រះសន្ធរក្ខិតោ សាន សាន់ | ២-លោកជំទាវ នូ សូលីដា |
| ៣-ឯកឧត្តម គង់ ស៊ីច័ន្ទ | ៤-ឯកឧត្តម ថន រិទ្ធី |

៥-លោកជំទាវ គីម ស៊ីថុន ៦-លោកជំទាវ ស៊ិយ សុខា

៧-លោក រៀម រ៉ាម៉ូ ៨-លោក សោម និស្ស័យ

**ឆ**- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១-លោក គ្រូក ថុនា ២-លោក សួន វិចិត្រ

៣-លោក បូរ ពេជ្រសិលា

**ជ**- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១-លោក ចាន់ ផេង ២-លោក ហ៊ុន សឿន

៣-លោក វឿន ខឿន ៤-អ្នកស្រី ប៉ូច រីម

៥-អ្នកស្រី មាស ម៉ូលីកា ៦-អ្នកស្រី នាង ស៊ីថា

៧-អ្នកស្រី សុទ្ធ ថាវី ៨-លោក វ៉ា វុង

៩-អ្នកស្រី រដ្ឋ ចន្ទី

**ឈ**- គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ**

១-ឧត្តមសេនីយ៍ឯក ស៊ូ សុផាន អត្តលេខ៧៣៩៩០ ២-ឧត្តមសេនីយ៍ឯក ហៃល ធីរិទ្ធ អត្តលេខ៦៧០០៦

៣-ឧត្តមសេនីយ៍ត្រី ប៊ុន ភក្តី អត្តលេខ៧០៨៥០ ៤-ឧត្តមសេនីយ៍ត្រី សេង ជាសុខ អត្តលេខ៩០៧៧៨

៥-ឧត្តមសេនីយ៍ត្រី សេង វាយោ អត្តលេខ៦៩៥៥៤ ៦-វរសេនីយ៍ឯក លី វុទ្ធី អត្តលេខ៩០៧៧៥

៧-វរសេនីយ៍ឯក ខេង ជិន អត្តលេខ៨៥៣៩៩ ៨-វរសេនីយ៍ឯក គង់ សីវឌ្ឍនា អត្តលេខ៦៤២១៨

៩-វរសេនីយ៍ទោ ទី ដារ៉ាវ័ន្ត អត្តលេខ០២៥០៦៤ ១០-វរសេនីយ៍ត្រី សេង សាម៉េង អត្តលេខ៨៤៣១០

១១-វរសេនីយ៍ឯក ម៉ុង សុខា អត្តលេខ៦៩១៨៦ ១២-វរសេនីយទោ កែវ យឿម អត្តលេខ៩១២៨២

១៣-វរសេនីយ៍ទោ ជា ពង្ស អត្តលេខ៩៣៣៦៩ ១៤-វរសេនីយ៍ទោ ថាត់ ឡុងឌី អត្តលេខ៧៣៧៧៣

១៥-វរសេនីយ៍ត្រី សូ សុវណ្ណដារ៉ា អត្តលេខ៦៧០៣៧ ១៦-វរសេនីយ៍ទោ សូ សុវណ្ណារិទ្ធ អត្តលេខ៦៤២២១

នស/រកត.៦៣០២.២៣៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២៣*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២៣៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ដំឡើងឋានៈឯកឧត្តម **ឈឹម សារ៉េត** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.ម៣០២.២៣៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/៥៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំង និងផ្តល់ឋានៈជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៣រូប៖

១- ឯកឧត្តម **ព្រាប ម៉ាណែល** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម **សូ ខនបញ្ញារិទ្ធិ** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម **ខៀវ សុខា** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

ពរស.២៣០៥.៥៧៤

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១:** ដំឡើងឋានៈ សមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ២រូបះ

១- ឯកឧត្តម **ជា ពិសី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **សុភ ឌុច** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរជ.២៣០២-២៣៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

សីហមុនី

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/៤៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង និងផ្តល់ឋានៈលោកជំទាវ **ឆួច សុផារត្ន** ជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរល. ២៣០៤.៤៣៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២១៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំងមុខតំណែងជា អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន ២រូបៈ

១- ឯកឧត្តម **ស៊ុំ ចន្ទ្សាន** បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **កែង សារ៉ៃ**

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ពរព. ២៣០២. ២១៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/៤៣៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងមុខតំណែង និងផ្តល់ឋានៈ ឯកឧត្តមឧត្តមសេនីយ៍ត្រី **ម៉ាត្រ សុត្រ** អត្តលេខ ១៦២០២ ជាអនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ មានឋានៈនិងបុព្វសិទ្ធិស្មើ **អគ្គនាយក** ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៧៣.២៣០២.៤៣៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ០៣ *ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានបម្លង់ត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្មដល់លោក **ឡូឆារើនវ៉ាថាណាឆៃ បំរុង** (LOCHAREONVATHANA CHAI BAMRUNG) ជនជាតិ ថៃ សញ្ជាតិ ថៃ កើតនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៥៦ នៅខេត្តប្រាជីនបុរី ព្រះរាជាណាចក្រថៃ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រ.ស.ប.២៣០២.២៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/៤៨០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

ឯកឧត្តម ថន អ៊ីម

៣៣៣.២៣០២.៤៨០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/ ៤៤១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស ដល់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ៥រូបៈ

- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តម **ម៉ុន ហុន**

២- ឯកឧត្តម **ឡាំ ជា**

៣- ឯកឧត្តម **សូ មុនីរក្សា**

៤- ឯកឧត្តម **ហ៊ីន យុថនា**

៥- ឯកឧត្តម **ខូយ រីដា**

១៣.២៣០២.៤៤១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ១៣ *ខែកុម្ភៈ ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២៣/២៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: ផ្តល់គោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ៩រូប ៖

| | | | | |
|---|---|---|---|---|
| ១- ព្រឹទ្ធាចារ្យសិល្បៈ | **គិន យិន** | ជា | គរុនាដកា | **គិន យិន** |
| ២- ព្រឹទ្ធាចារ្យ | **ជា យុទ្ធា** | ជា | ទេពហត្ថកោសល្យ | **ជា យុទ្ធា** |
| ៣- ព្រឹទ្ធាចារ្យសិល្បៈ | **ឡៀន សុផាន** | ជា | ចម្មការភិរក្ស | **ឡៀន សុផាន** |
| ៤- ព្រឹទ្ធាចារ្យសិល្បៈ | **ញូច ហឿន** | ជា | ពិភត្តិតន្ត្រី | **ញូច ហឿន** |
| ៥- ព្រឹទ្ធាចារ្យសិល្បៈ | **ណាន សាម័យ** | ជា | នាដកីនិម្មិត | **ណាន សាម័យ** |
| ៦- ព្រឹទ្ធាចារ្យ | **ប៊ិន ទិន** | ជា | បោរាណាចារ្យ | **ប៊ិន ទិន** |
| ៧- ព្រឹទ្ធាចារ្យ | **ម៉ក់ ជាង** | ជា | ទេពសោភ័ណ | **ម៉ក់ ជាង** |

៨- ព្រឹទ្ធាចារ្យសិល្បៈ **ឯល ពេជ** ជា ទេពវោហារ **ឯល ពេជ**

៩- ព្រឹទ្ធាចារ្យ **អ៊ឹម ស្រួន** ជា មហានាដកគរុវិជ្ជា **អ៊ឹម ស្រួន**

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

នស/រកត/០២២៣/២៤៣

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៦១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមន្ទីរពេទ្យជាតិ តេជោសន្តិភាព ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៦/០១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ

- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យ លេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានឈ្មោះថា មន្ទីរពេទ្យជាតិ តេជោសន្តិភាព សរសេរជាអក្សរកាត់ថា "**ម.ជ.ត.ស.**" ឈ្មោះជាភាសាអង់គ្លេសថា "TECHO SANTEPHEAP NATIONAL HOSPITAL" និងសរសេរជាអក្សរកាត់ជាភាសាអង់គ្លេសថា "TSNH" ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស គឺក្រសួងសុខាភិបាល និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២.-**

**ម.ជ.ត.ស.** ជានីតិបុគ្គលនៃនីតិសាធារណៈ និងមានថវិកាស្វយ័តដែលត្រូវឆ្លុះបញ្ចាំង ជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសុខាភិបាល។

**ម.ជ.ត.ស.** មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅមហាវិថីឈ្មោះឈ្មោះ ភូមិកប់ស្រូវធំ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

**មាត្រា៣.-**

**ម.ជ.អ.ស.** មានភារកិច្ចដូចខាងក្រោម៖

- ផ្តល់សេវាសុខាភិបាលពិគ្រោះ ពិនិត្យ និងព្យាបាលជំងឺគ្រប់ប្រភេទ ដោយមិនមានការរើសអើង ប្រកបដោយការទទួលខុសត្រូវនៃវិជ្ជាជីវៈមានជាអាទិ៍៖ ជំងឺឆ្លងគ្រប់ប្រភេទ ជំងឺវេជ្ជសាស្ត្រទូទៅ សល្យសាស្ត្រ ទន្តសាស្ត្រ សម្ភព រោគស្ត្រី ការថែទាំព្យាបាលមនុស្សចាស់ ប្រព័ន្ធរំលាយអាហារ លាងឈាម ស្តារនីតិកាយសម្បទា និង ផ្តល់ការវះកាត់ ជាពិសេសការវះកាត់បាក់បែកឆ្អឹង និង សរសៃប្រសាទ ត្រចៀកច្រមុះ បំពង់ក ត្រមង់នោម ពោះ ទ្រូង សោភ័ណសល្យសាស្ត្រ និងឯកទេសផ្សេងៗទៀត តាមលទ្ធភាពរបស់មន្ទីរពេទ្យ
- សហការក្នុងផ្នែកវេជ្ជសាស្ត្របង្ការការពារ និង ផ្តល់សេវាសម្រាប់វេជ្ជសាស្ត្រអាសន្ន
- ចាត់វិធានការ ដើម្បីឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ ឬរ៉ាប់រងសម្រួលឱ្យអ្នកជំងឺមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬទៅព្យាបាលនៅមន្ទីរពេទ្យដទៃទៀត
- ផ្តល់ ឬអាចសហការក្នុងការបណ្តុះបណ្តាល កម្មសិក្សា និង ស្រាវជ្រាវវិស័យវេជ្ជសាស្ត្រ ថែទាំវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឱសថសាស្ត្រ និង សុខភាពសាធារណៈ ដល់បុគ្គលិក និស្សិតមុន និងក្រោយឧត្តមសិក្សា
- សហប្រតិបត្តិការជាមួយដៃគូ ស្ថាប័នជាតិ និង អន្តរជាតិ ព្រមទាំងវិស័យឯកជនលើការអភិវឌ្ឍវិស័យវិទ្យាសាស្ត្រសុខាភិបាល។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាលរបស់ ម.ជ.អ.ស.

**មាត្រា៤.-**

**ម.ជ.អ.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្មតម្រង់ទិសការអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងាររបស់ **ម.ជ.អ.ស.** ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

**ម.ជ.អ.ស.** មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន៥(ប្រាំ)រូប ដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - តំណាងក្រសួងសុខាភិបាល | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងឥស្សរជនដែលមានចំណេះដឹង និងបទពិសោធន៍ ខាងផ្នែកវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| - នាយក **ម.ជ.អ.ស.** | សមាជិក |

- តំណាងបុគ្គលិកនៃ **ម.ជ.ត.ស.** សមាជិកស្វ័យប្រវត្តិ។

ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ត.ស.** ត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ ១(មួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត **ម.ជ.ត.ស.** ។

**មាត្រា៦.-**

តំណាងបុគ្គលិកនៃ **ម.ជ.ត.ស.** ១(មួយ)រូប គឺជាសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិកសម្រាប់អាណត្តិ ៣(បី)ឆ្នាំ។ តំណាងបុគ្គលិកត្រូវក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោត ដោយមិនចាំបាច់មានការតែងតាំងឡើយ។ នៅពេលចប់អាណត្តិ ឬលាឈប់ពីការងារ តំណាងបុគ្គលិកនេះ ត្រូវបាត់បង់សមាជិកភាពក្រុមប្រឹក្សាភិបាលដោយស្វ័យប្រវត្តិ។

តំណាងបុគ្គលិក ត្រូវជ្រើសរើសដោយការបោះឆ្នោត ដែលប្រព្រឹត្តទៅតាមលក្ខណៈប្រជាធិបតេយ្យ។ អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់៖

ក. អាណត្តិដំបូងនៃក្រុមប្រឹក្សាភិបាលជាបុគ្គលិកអចិន្ត្រៃយ៍។

ខ. អាណត្តិនៃក្រុមប្រឹក្សាភិបាលបន្តបន្ទាប់ទៀត ជាបុគ្គលិកទាំងអស់ ដែលមានសិទ្ធិបោះឆ្នោតតាមការសម្រេចរបស់នាយក **ម.ជ.ត.ស.** ។

តំណាងនេះ ត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ស្របតាមលក្ខខណ្ឌនិច្ច័យដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ មានអាយុយ៉ាងតិច ២៥(ម្ភៃប្រាំ)ឆ្នាំ និងយ៉ាងច្រើន ៥៥(ហាសិបប្រាំ)ឆ្នាំ
- បម្រើការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំ ដោយយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍ឱ្យបុគ្គលិកទាំងអស់ និង **ម.ជ.ត.ស.**
- មានកិរិយាមាយាទល្អ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ដែលពាក់ព័ន្ធនឹងទំនុកចិត្ត និង សមត្ថភាពវិជ្ជាជីវៈ
- មានសមត្ថភាព និងបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់តាមសំណូមពរ និងលក្ខខណ្ឌនៃការងាររបស់ **ម.ជ.ត.ស.**
- នីតិវិធីសម្រាប់ការបោះឆ្នោតតំណាងបុគ្គលិកជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិនីមួយៗនៃ **ម.ជ.ត.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយក **ម.ជ.ត.ស.** ។

ក្រៅពីសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀត ត្រូវមានអាណត្តិ ៣(បី)ឆ្នាំ ដែលត្រូវបានតែងតាំង និងបញ្ចប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័នដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះ អាចបន្តសារជាថ្មីទៀតបានដោយអនុក្រឹត្យ ប៉ុន្តែមិនត្រូវលើសពី ២(ពីរ)អាណត្តិឡើយ។

**មាត្រា៧.-**

បេក្ខភាពជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការឬឥស្សរជនដែលមានលក្ខណសម្បត្តិ និងបទពិសោធន៍ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ

- បម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពវិជ្ជាជីវៈ
- មានសមត្ថភាពជំនាញនៅក្នុងវិស័យពាក់ព័ន្ធជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។

**មាត្រា៨**.-

សមាជិកភាពក្រុមប្រឹក្សាភិបាល អាចត្រូវបានបញ្ចប់មុនអាណត្តិតាមសំណើក្រសួង ស្ថាប័នតំណាង ក្នុងករណីដែល សមាជិកក្រុមប្រឹក្សាភិបាលនោះមានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័ន តំណាងបុគ្គលិករបស់ **ម.ជ.ឥ.ស.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

ក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវបន្តនិន្តរភាពការងាររបស់ខ្លួន រហូតដល់មានការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ត្រូវតែងតាំងយ៉ាងយូរបំផុត ១(មួយ)ខែ ក្រោយការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាលចាស់។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ក្រសួងសុខាភិបាលត្រូវរៀបចំសំណើទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិថ្មី។ ក្រសួងសុខាភិបាលត្រូវទទួលខុសត្រូវលើភាពយឺតយ៉ាវនៃការស្នើតែងតាំងក្រុមប្រឹក្សាភិបាល។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវមានបញ្ជាក់អំពីអាណត្តិ ដែលសមាជិកនោះត្រូវទទួល។

សមាជិកក្រុមប្រឹក្សាភិបាលថ្មី ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរ ស្របតាមលក្ខខណ្ឌខាងលើមានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាល។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាល **ម.ជ.ឥ.ស.** មានវិសមិតភាពជាមួយមុខងារជានាយក **ម.ជ.ឥ.ស.**។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល មានវិសមិតភាពមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជាបន្ទុករបស់ **ម.ជ.ឥ.ស.** លើកលែងតែករណី ដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ។

សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

សមាជិកក្រុមប្រឹក្សាភិបាល មានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញ ប្រកាន់ខ្ជាប់នូវគោលជំហរ ពាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន ជូនក្រសួង ស្ថាប័ន ដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ឥ.ស.** ។

**មាត្រា៩.-**

សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប នឹងទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមគោលការណ៍កំណត់ជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ឥ.ស.** ត្រូវសម្រេចជាគោលការណ៍ ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ អាចត្រូវបានផ្អាកដោយក្រសួង ស្ថាប័ន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ពុំគោរពអាណត្តិកិច្ចរបស់ខ្លួន ដែលមានជាអាទិ៍គឺ៖

១.ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងមនសិការវិជ្ជាជីវៈ

២.ការគោរពបទបញ្ជា និងបទប្បញ្ញត្តិរបស់ **ម.ជ.ឥ.ស.**

៣.ការបំពេញតួនាទី និងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល

៤.ការអនុវត្តកាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័ន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ។

ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើវិស័យពាក់ព័ន្ធ ជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍន៍ ឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា១០.-**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសកម្មភាពការងារ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ម.ជ.ឥ.ស.**។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍របស់ **ម.ជ.ឥ.ស.** ទាំងសម្រាប់រយៈពេលមធ្យមទាំងសម្រាប់រយៈពេលវែង
- ពិនិត្យ និងអនុម័តគម្រោងថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ម.ជ.ឥ.ស.**
- ពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រង **ម.ជ.ឥ.ស.** របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះ **ម.ជ.ឥ.ស.**
- ជំរុញដំណើរការរបស់គណៈកម្មាធិការ និងគណៈកម្មការ ដែលបង្កើតឡើងដោយអនុក្រឹត្យស្តីពីការបង្កើត **ម.ជ.ឥ.ស.** ព្រមទាំងបង្កើតគណៈកម្មាធិការ និងគណៈកម្មការនានា តាមការចាំបាច់
- កំណត់នូវនីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិ ឬការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពិនិត្យ និងអនុម័តលើសំណើសុំកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់នាយក **ម.ជ.ឥ.ស.**
- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើក វិធានការកែតម្រូវសម្រាប់អនុវត្តបន្ត។

**មាត្រា១១.-**

យ៉ាងយូរ ១(មួយ)ខែក្រោយការបង្កើតក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង ដែលរបៀបវារៈសំខាន់គឺ ការរៀបចំសេចក្តីព្រាងប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃ **ម.ជ.ត.ស.** ដែលក្នុងនោះ ត្រូវបញ្ជាក់ពីរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះ **ម.ជ.ត.ស.** នោះ។

ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ត.ស.** មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញ តាមគំនិតផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២ ភាគ ៣ ឬពីនាយក **ម.ជ.ត.ស.** តាមការចាំបាច់។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងការអនុវត្តថវិកា ការពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ។

នាយក **ម.ជ.ត.ស.** ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសមន្ត្រីម្នាក់ជាលេខាធិការនៃអង្គប្រជុំ។ លេខាធិការនេះពុំមានសិទ្ធិបោះឆ្នោតទេ។

ក្រុមប្រឹក្សាភិបាល ធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការងារដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា៣៥ នៃអនុក្រឹត្យនេះ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី ៥០(ហាសិប)ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមាន ពុំអាចឱ្យគេជំនួសបានឡើយ។

ប្រសិនបើកូរ៉ុមមិនគ្រប់គ្រាន់ នោះប្រធានក្រុមប្រឹក្សាភិបាល អាចកោះអញ្ជើញប្រជុំជាថ្មី ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ ដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី ១(មួយ)ប៉ុណ្ណោះ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ប្រធាន និងត្រូវរក្សាទុកនៅទីស្នាក់ការរបស់ **ម.ជ.ត.ស.** ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុ ត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវរៀបចំ និងផ្ញើសេចក្តីព្រាងកំណត់ហេតុ ជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល ២(ពីរ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ នីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបាន

កំណត់ហេតុប្រជុំ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលត្រូវចុះហត្ថលេខាលើកំណត់ហេតុ ដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើ ត្រូវបញ្ជូនក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ។

ការប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវធ្វើឡើងជាចាំបាច់ ដោយមិនត្រូវឆ្លងខែបន្ទាប់នៃដំណាច់ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ គឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

## ផ្នែកទី២
## អង្គភាពប្រតិបត្តិរបស់ ម.ជ.អ.ស.

**មាត្រា១២.-**

**ម.ជ.អ.ស.** ត្រូវគ្រប់គ្រងដោយនាយក ១(មួយ)រូប ដែលត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែង ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសុខាភិបាល។ នាយក **ម.ជ.អ.ស.** មានតួនាទីជានាយកប្រតិបត្តិ។ ការតែងតាំងនាយក ត្រូវធ្វើឡើងយ៉ាងយូរ ១(មួយ)ខែ ក្រោយពីការចូលជាធរមាននៃអនុក្រឹត្យនេះ។

មុខងារជានាយក **ម.ជ.អ.ស.** មានវិសមិតភាពជាមួយមុខងារ ជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល។ យ៉ាងយូរ ១(មួយ)ខែ ក្រោយការតែងតាំង នាយក **ម.ជ.អ.ស.** ត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។

**មាត្រា១៣.-**

នាយក **ម.ជ.អ.ស.** គឺជាតំណាងរបស់ **ម.ជ.អ.ស.** ក្នុងទំនាក់ទំនងជាមួយតតិយជន។

នាយក **ម.ជ.អ.ស.** មានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនិងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ **ម.ជ.អ.ស.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.អ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ម.ជ.អ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត

- រៀបចំរបាយការណ៍គ្រប់គ្រង **ម.ជ.ត.ស.** របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់របស់ **ម.ជ.ត.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជាទៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ នូវភារកិច្ចរបស់អង្គភាពចំណុះនានានៃ **ម.ជ.ត.ស.**
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនមន្ត្រីរាជការនិងបុគ្គលិករបស់ **ម.ជ.ត.ស.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកគ្រប់ប្រភេទជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយដទៃទៀត ដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ម.ជ.ត.ស.** មានសិទ្ធិស្នើទៅក្រសួងសុខាភិបាលសុំតែងតាំងនាយករង ១ (មួយ)រូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់។ នាយករង ត្រូវមានចំណេះដឹងលើផ្នែកបច្ចេកទេសតាមវិស័យនីមួយៗ ដែលត្រូវទទួលគ្រប់គ្រង។

## ផ្នែកទី៣
## បុគ្គលិករបស់ ម.ជ.ត.ស.

**មាត្រា១៤.-**

បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ជ.ត.ស.** គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅក្នុង **ម.ជ.ត.ស.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ម.ជ.ត.ស.** អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិករបស់ **ម.ជ.ត.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្ដីពីបុគ្គលិក ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបំពេញភារកិច្ចនៅ **ម.ជ.ឥ.ស.** ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗក្រៅពីថវិការដ្ឋជូនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកជាប់កិច្ចសន្យានៃ **ម.ជ.ឥ.ស.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់នាយក **ម.ជ.ឥ.ស.** បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់ ម.ជ.ឥ.ស.

**មាត្រា១៥.-**

**ម.ជ.ឥ.ស.** ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ម.ជ.ឥ.ស.** មានទ្រព្យសម្បត្តិ ដែលរួមមាន៖

ក. ធនធានគ្រាដំបូងទទួលបានពីរដ្ឋ ដែលមានបញ្ជាក់ក្នុងតារាងតុល្យការ ភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យបង្កើត **ម.ជ.ឥ.ស.** នេះ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួង រវាងក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាព និងចុះហត្ថលេខាពីក្រសួង ស្ថាប័នអាណាព្យាបាលទាំងពីរ។ តារាងតុល្យការ ត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ រួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា។

ខ. ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដែលអាចរកបានក្រោយថ្ងៃបង្កើត **ម.ជ.ឥ.ស.** ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ម.ជ.ឥ.ស.** ត្រូវបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **ម.ជ.ឥ.ស.**។ នាយក **ម.ជ.ឥ.ស.** ដែលជាប្រធាន និងសមាជិកដទៃទៀតនៃគណៈកម្មការនេះ ត្រូវទទួលខុសត្រូវ និងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌ ដែលបានរៀបចំរួច។ ការរៀបចំបញ្ជីសារពើភណ្ឌ ត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗ ឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយដោយអនុលោមទៅតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ម.ជ.ឥ.ស.** មានភារកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ កើនឡើង និងថយចុះប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវ ដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចហើយត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរនៅចុងត្រីមាសទី ១(មួយ) នៃឆ្នាំបន្ទាប់។

**ម.ជ.ឥ.ស.** អាចធ្វើការទិញ-លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យ លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌ និងនីតិវិធីនៃការទិញ-លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមការសម្រេច

របស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ ហើយត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែល **ម.ជ.អ.ស.** ត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយអនុក្រឹត្យ ទ្រព្យសកម្មដែលជាចលនទ្រព្យ និងអចលនទ្រព្យរបស់ **ម.ជ.អ.ស.** ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុ ត្រូវបង្វែរចូលគណនីទោលរតនាគារ។

## ផ្នែកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.ជ.អ.ស.

**មាត្រា១៦.-**

**ម.ជ.អ.ស.** ត្រូវមានគណនេយ្យភាពចំពោះក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ លើការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៧.-**

នាយក **ម.ជ.អ.ស.** ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់ **ម.ជ.អ.ស.** ដែលទទួលបានការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលជាអាណាប័កដើមខ្សែ មានសិទ្ធិអំណាចដូចតទៅះ

- បញ្ជា និងជម្រះចំណូល
- បញ្ជាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ នាយក **ម.ជ.អ.ស.** អាចផ្ទេរសិទ្ធិនេះបន្តឱ្យអាណាប័កជំនួសដោយមានការយល់ព្រមពីអាណាប័កដើមខ្សែ។

ក្រសួងសុខាភិបាលត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ **ម.ជ.អ.ស.** តាមសំណើរបស់នាយក **ម.ជ.អ.ស.** និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅ **ម.ជ.អ.ស.**។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោមៈ

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រឡើង ផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ៣(បី)ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់បញ្ជីគណនេយ្យ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។

គណនេយ្យករ ត្រូវមានគុណវុឌ្ឍិ និងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ គ្រប់គ្រាន់ ព្រមទាំងបំពេញលក្ខខណ្ឌផ្សេងទៀត ដែលស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណនេយ្យករ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណនេយ្យករត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់។

គណនេយ្យករ មានភារកិច្ច ៖

- គ្រប់គ្រងការប្រមូលចំណូល
- ទូទាត់ចំណាយ
- រក្សាទុក និងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **ម.ជ.ត.ស.**។

គណនេយ្យករអាចមានមន្ត្រីជំនាញមួយចំនួនជាជំនួយការក្នុងការបំពេញមុខងាររបស់ខ្លួន។

**មាត្រា១៩.-**

ប្រភពធនធានរបស់ **ម.ជ.ត.ស.** រួមមាន៖

- ធនធានដំបូងរបស់រដ្ឋផ្តល់ជូន **ម.ជ.ត.ស.** នៅពេលចាប់ផ្តើមបង្កើតដំបូង ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យនេះ
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានគ្រោងក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភធនសម្រាប់ ដំណើរការ និងឧបត្ថម្ភកធនជាមូលធន
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ជ.ត.ស.** បានទទួល
- កម្រៃសេវាសាធារណៈ ឬភាគទានដែល **ម.ជ.ត.ស.** មានសិទ្ធិប្រមូល ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- កម្រៃពីទ្រព្យសម្បត្តិរបស់ **ម.ជ.ត.ស.** និងចំណូលពីការលក់ទ្រព្យសម្បត្តិទាំងនោះ ស្របតាម ការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២០.-**

ចំណូល ចំណាយចរន្ត និងមូលធនរបស់ **ម.ជ.ត.ស.** ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ត.ស.** និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិកាក្រសួងសុខាភិបាល។ ចំណូលរបស់ **ម.ជ.ត.ស.** រួមមានការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗ ស្របតាមមាត្រា១៩។

ថវិកាត្រូវរៀបចំដោយនាយក **ម.ជ.ត.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងសុខាភិបាលពិនិត្យ និងសម្រេច មុននឹងបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ថវិកា ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

ចំណូល និងចំណាយរបស់ **ម.ជ.ត.ស.** ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិការដ្ឋដែរ។

ចំណាយ ត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

**ម.ជ.ឥ.ស.** មិនអាចបង្កើតលក្ខខណ្ឌ ដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២១.-**

គណនេយ្យរបស់ **ម.ជ.ឥ.ស.** រួមមាន៖

- គណនេយ្យទូទៅដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

កិច្ចបញ្ជិកាគណនេយ្យរបស់ **ម.ជ.ឥ.ស.** ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ។

**ម.ជ.ឥ.ស.** ត្រូវអនុវត្តកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលតាមគោលការណ៍ណែនាំសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានជាធរមាន ។

**មាត្រា២២.-**

ថវិការបស់ **ម.ជ.ឥ.ស.** គឺជាមូលនិធិសាធារណៈរបស់រដ្ឋ។

ថវិការបស់ **ម.ជ.ឥ.ស.** ដែលមានប្រភពឧបត្ថម្ភធនពីថវិការដ្ឋ ត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យ **ម.ជ.ឥ.ស.** ប្រើប្រាស់គណនីនៅធនាគារពាណិជ្ជ សម្រាប់គ្រប់គ្រងថវិកា ដែលបានមកពីចំណូលផ្ទាល់ និងពីប្រភពផ្សេងៗទៀត។

អតិរេករបស់ **ម.ជ.ឥ.ស.** ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ អតិរេកនេះត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អតិរេកនេះ អាចត្រូវបានចាត់ចែង សម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយប្រតិបត្តិការនាការិយបរិច្ឆេទបន្ទាប់ និង/ឬសម្រាប់ការវិនិយោគជាប្រយោជន៍ដល់អភិវឌ្ឍន៍ **ម.ជ.ឥ.ស.** ឬជាកម្មវត្ថុនៃការបង់ចូលថវិកាជាតិ។ ការចាត់ចែងអតិរេកនេះ ត្រូវមានការយល់ព្រមពីក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី ៦
## របបសារពើពន្ធរបស់ ម.ជ.ឥ.ស.

**មាត្រា២៣.-**

**ម.ជ.ឥ.ស.** ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់។

## ផ្នែកទី ៧
## ការងារលទ្ធកម្មរបស់ ម.ជ.ត.ស.

**មាត្រា២៤.-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មក្នុង **ម.ជ.ត.ស.** ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣
## អាណាព្យាបាលភាព

**មាត្រា២៥.-**

**ម.ជ.ត.ស.** មានអាណាព្យាបាល ២ (ពីរ) ដូចខាងក្រោម៖

១. អាណាព្យាបាលបច្ចេកទេស គឺក្រសួងសុខាភិបាល ។

២. អាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានថវិកាជាសេនាធិការក្នុងការសម្របសម្រួលគ្រប់គ្រង **ម.ជ.ត.ស.**។

**មាត្រា២៦.-**

អាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ អាចចាត់មន្ត្រីមានសមត្ថកិច្ចឱ្យធ្វើអធិការកិច្ច សវនកម្ម តាមដាន និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការនានារបស់ **ម.ជ.ត.ស.** តាមការចាំបាច់។

**មាត្រា២៧.-**

**ម.ជ.ត.ស.** ត្រូវផ្តល់ជូនអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ **ម.ជ.ត.ស.** ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការពិនិត្យនិងអនុម័ត ដោយក្រុមប្រឹក្សាភិបាលនូវឯកសារដូចខាងក្រោម៖

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍ **ម.ជ.ត.ស.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ត.ស.**
- របាយការណ៍គ្រប់គ្រង **ម.ជ.ត.ស.** របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុ។

ទទួលបានឯកសារខាងលើ អាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ **ម.ជ.ត.ស.** ត្រូវចាត់ការបន្តតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៨.-**

អាណាព្យាបាលបច្ចេកទេសមានភារកិច្ច ដូចខាងក្រោម៖

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ **ម.ជ.ឥ.ស.** អនុវត្ត
- ពិនិត្យ និងសម្រេចផែនការអភិវឌ្ឍន៍របស់ **ម.ជ.ឥ.ស.**
- ពិនិត្យ និងសម្រេចលើសេចក្តីព្រាង នៃគម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ឥ.ស.**
- ពិនិត្យ និងសម្រេចលើសំណើចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ
- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់ **ម.ជ.ឥ.ស.**
- ដាក់ចេញនូវវិធានការកែលម្អនានាពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់ **ម.ជ.ឥ.ស.** ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធនៃ **ម.ជ.ឥ.ស.**
- ស្នើតែងតាំងនាយក **ម.ជ.ឥ.ស.**
- តែងតាំងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅ **ម.ជ.ឥ.ស.** អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ **ម.ជ.ឥ.ស.**។

**មាត្រា២៩.-**

អនុលោមតាមបទប្បញ្ញត្តិជាធរមាន អាណាព្យាបាលបច្ចេកទេស ត្រូវផ្ញើជូនអាណាព្យាបាលហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ នូវការសម្រេចទាំងឡាយរបស់ខ្លួន និងរបស់ក្រុមប្រឹក្សាភិបាល ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យ និងសម្រេចមានជាអាទិ៍៖

- ផែនការអភិវឌ្ឍន៍ **ម.ជ.ឥ.ស.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ឥ.ស.**
- ការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- សេចក្តីសម្រេចផ្សេងទៀតដែលអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

**មាត្រា៣០.-**

អាណាព្យាបាលបច្ចេកទេស មានសិទ្ធិលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹង **ម.ជ.ឥ.ស.** ក្នុងករណីដែល ៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ម.ជ.ឥ.ស.** ផ្ទុយនឹងគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់ **ម.ជ.ឥ.ស.** ក៏ដូចជារបស់ក្រសួងសុខាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ម.ជ.ឥ.ស.** ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- សេចក្តីសម្រេចធ្វើឡើងដោយក្រសួង ស្ថាប័ន អាជ្ញាធរ ដែលមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬ សេចក្តីសម្រេចធ្វើឡើងដោយការប្រជុំក្រុមប្រឹក្សាភិបាល ដែលពុំអនុលោមតាមនីតិវិធី
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកខាងលើនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសុខាភិបាល ដោយមានបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ក្រសួងសុខាភិបាល ត្រូវជូនដំណឹងអំពីប្រកាសនេះ ដល់នាយក **ម.ជ.ត.ស.**។ នាយក **ម.ជ.ត.ស.** ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា៣១.-**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល ឬនាយក **ម.ជ.ត.ស.** ពុំប្រតិបត្តិតាមបណ្តាវិធានដែលមានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ត.ស.** ក្រសួងសុខាភិបាល អាចចេញសេចក្តីសម្រេច និងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា៣២.-**

អាណាព្យាបាលហិរញ្ញវត្ថុ មានភារកិច្ច៖

- ពិនិត្យ និងផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍ **ម.ជ.ត.ស.**
- ពិនិត្យ និងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ត.ស.**
- ពិនិត្យ និងអនុម័តផែនការលទ្ធកម្មរបស់ **ម.ជ.ត.ស.**
- ពិនិត្យ និងសម្រេចលើការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- ពិនិត្យ និងផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យនិងសម្រេចលើសេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យ និងសម្រេច ឬផ្តល់ការយល់ព្រម លើឯកសារផ្សេងទៀត តាមសំណើរបស់ក្រសួងសុខាភិបាល ឬនាយក **ម.ជ.ត.ស.** ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំ និងដាក់ឱ្យអនុវត្តនូវវិធាននិងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និងបទដ្ឋានគតិយុត្តទាំងឡាយដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ **ម.ជ.ត.ស.** ។

**មាត្រា៣៣.-**

សេចក្តីសម្រេចរបស់នាយក **ម.ជ.ត.ស.** ក្រុមប្រឹក្សាភិបាល និងរបស់អាណាព្យាបាលបច្ចេកទេស ដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៣២ នៃអនុក្រឹត្យនេះ ពុំមានអានុភាពអនុវត្តឡើយ ក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងនាយក ម.ត.ស. នូវការជំទាស់របស់ខ្លួន ដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់។ នាយក **ម.ជ.ត.ស.** និងក្រុមប្រឹក្សាភិបាលនិង

អាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យ និងដោះស្រាយឱ្យបានឆាប់បំផុត នូវករណីដែលបានលើកឡើងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣៤.-**

អាណាព្យាបាលហិរញ្ញវត្ថុ អាចលុប ឬផ្អាក ការអនុវត្តសេចក្តីសម្រេចចិត្តពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុរបស់នាយក **ម.ជ.អ.ស.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់នាយក **ម.ជ.អ.ស.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកទុកនេះ ត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងដល់អាណាព្យាបាលបច្ចេកទេស និងនាយក **ម.ជ.អ.ស.** ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា៣៥.-**

អាណាព្យាបាលហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១(មួយ)រូបប្រចាំ **ម.ជ.អ.ស.** ដើម្បីបំពេញមុខងារ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន ។

## ជំពូកទី៤
## ការត្រួតពិនិត្យ

**មាត្រា៣៦.-**

**ម.ជ.អ.ស.** ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា៣៧.-**

**ម.ជ.អ.ស.** ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច សវនកម្ម តាមដាន ត្រួតពិនិត្យដោយអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិស្របតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ **ម.ជ.អ.ស.** អាចត្រូវបានតម្រូវឱ្យស្ថិតក្រោមការធ្វើសវនកម្មដោយសវនករឯករាជ្យដោយមានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

១៧/១៨

**មាត្រា៣៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៧ ខែមីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរយោធិនពិការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១:** ផ្ទេរយោធិនពិការ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម៖

១- ឧត្តមសេនីយ៍ឯក **ចៅ ស៊ូរីការ៉ាន** អត្តលេខ០០១១៦៥ កងឯកភាព អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

| | | | |
|---|---|---|---|
| ២- ឧត្តមសេនីយ៍ឯក | ខួន វ៉ុនថុន | អត្តលេខ០០០៦៧៣ | កងឯកភាព អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ |
| ៣- ឧត្តមសេនីយ៍ឯក | ឃួន សុភាព | អត្តលេខ០២៥០៧២ | កងឯកភាព នាយកដ្ឋានអប់រំ |
| ៤- ឧត្តមសេនីយ៍ឯក | ជ័យ ផល្គុន | អត្តលេខ០០៣១៩៩ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ៥- ឧត្តមសេនីយ៍ឯក | អ៊ិន សុវណ្ណា | អត្តលេខ០២៥០១៥ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ៦- ឧត្តមសេនីយ៍ឯក | មាឃ សម្បត្តិ | អត្តលេខ០១៣៨៩៧ | កងឯកភាព នាយកដ្ឋានវិស្វកម្ម |
| ៧- ឧត្តមសេនីយ៍ឯក | ខៀវ ចាន់នៅ | អត្តលេខ០១៤១៩៩ | កងឯកភាព នាយកដ្ឋានវិស្វកម្ម |
| ៨- ឧត្តមសេនីយ៍ឯក | ផាត និល | អត្តលេខ០១៣៨២០ | កងឯកភាព នាយកដ្ឋាននីតិកម្ម |
| ៩- ឧត្តមសេនីយ៍ឯក | និន ភិរម្យ | អត្តលេខ០១៦៨៤៩ | កងឯកភាព មជ្ឈមណ្ឌលកីឡាកងយោធពល ខេមរភូមិន្ទ |
| ១០-ឧត្តមសេនីយ៍ឯក | ខិន សេង | អត្តលេខ០២៦០៣៧ | កងឯកភាព មជ្ឈមណ្ឌលកីឡាកងយោធពល ខេមរភូមិន្ទ |
| ១១-ឧត្តមសេនីយ៍ឯក | ណូន រ៉ែន | អត្តលេខ០២៦៩៥០ | កងឯកភាព នាយកដ្ឋានអភិវឌ្ឍន៍ |
| ១២-ឧត្តមសេនីយ៍ឯក | មុំ សំអាន | អត្តលេខ១៤៥៤៨២ | កងឯកភាព នាយកដ្ឋានផលិតសម្ភារៈ យោធា |
| ១៣-ឧត្តមសេនីយ៍ឯក | នួន សំបូរ | អត្តលេខ០០០៥៥៦ | កងឯកភាព នាយកដ្ឋានភូមិសាស្ត្រ |
| ១៤-ឧត្តមសេនីយ៍ឯក | ជា ឆេន | អត្តលេខ០០១៦២១ | កងឯកភាព នាយកដ្ឋានកិច្ចការ យោធា ស៊ីវិល |
| ១៥-ឧត្តមសេនីយ៍ទោ | គង់ ធី | អត្តលេខ០១០១៧២ | កងឯកភាព នាយកដ្ឋានប្រេងឥន្ធនៈ |
| ១៦-ឧត្តមសេនីយ៍ទោ | ង៉ោ ធឿន | អត្តលេខ០២៨៨៨០ | កងឯកភាព នាយកដ្ឋានកិច្ចការ យោធា ស៊ីវិល |
| ១៧-ឧត្តមសេនីយ៍ទោ | ខោល សុខុម | អត្តលេខ០០៩១១០ | កងឯកភាព កងពលតូចដឹកជញ្ជូនលេខ៩៩ |
| ១៨-ឧត្តមសេនីយ៍ទោ | ឃ្លាំង ឫទ្ធី | អត្តលេខ០២៥០៩៥ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ១៩-ឧត្តមសេនីយ៍ទោ | ជា គឹមសុខ | អត្តលេខ២៣១៧៧៧ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ២០-ឧត្តមសេនីយ៍ទោ | ម៉ម រម្មណីយ៍ | អត្តលេខ០១៤១៥២ | កងឯកភាព នាយកដ្ឋានហិរញ្ញវត្ថុ |
| ២១-ឧត្តមសេនីយ៍ទោ | ជា សុវណ្ណា | អត្តលេខ០១៣៨៥៣ | កងឯកភាព នាយកដ្ឋានផ្គត់ផ្គង់ |
| ២២-ឧត្តមសេនីយ៍ទោ | ម៉ៅ ជៀប | អត្តលេខ០៣៥០១២ | កងឯកភាព នាយកដ្ឋានយានយន្ត |
| ២៣-ឧត្តមសេនីយ៍ត្រី | គង់ ម៉ុនលី | អត្តលេខ០១៤២៩៩ | កងឯកភាព នាយកដ្ឋានប្រេងឥន្ធនៈ |
| ២៤-ឧត្តមសេនីយ៍ត្រី | ខាន វណ្ណៈ | អត្តលេខ០៨២៩៨៧ | កងឯកភាព សាកលវិទ្យាល័យការពារជាតិ |
| ២៥-ឧត្តមសេនីយ៍ត្រី | ឃុន ណៃ | អត្តលេខ០៤៩១៣២ | កងឯកភាព កងពលតូចដឹកជញ្ជូនលេខ៩៩ |
| ២៦-ឧត្តមសេនីយ៍ត្រី | សែម វី | អត្តលេខ០៥០១០៦ | កងឯកភាព នាយកដ្ឋានអភិវឌ្ឍន៍ |
| ២៧-ឧត្តមសេនីយ៍ត្រី | ស្រៀង អ៊ាងលី | អត្តលេខ០២៥០៣៨ | កងឯកភាព នាយកដ្ឋានទាក់ទងអន្តរជាតិ |

| | | | |
|---|---|---|---|
| ២៨-ឧត្តមសេនីយ៍ត្រី | ចាយ ជឿន | អត្តលេខ០១៩៧៤៨ | កងឯកភាព វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល |
| ២៩-ឧត្តមសេនីយ៍ត្រី | ចន្ទ្រ សុភ័ក្ត្រ | អត្តលេខ០០៨៣៨៩ | កងឯកភាព នាយកដ្ឋានយានយន្ត |
| ៣០-ឧត្តមសេនីយ៍ត្រី | ជុំ សុវណ្ណា | អត្តលេខ០១៥៩១២ | កងឯកភាព នាយកដ្ឋានផលិតសម្ភារៈយោធា |
| ៣១-ឧត្តមសេនីយ៍ត្រី | ម៉ក់ ចាន់ថុល | អត្តលេខ០៣១០១៨ | កងឯកភាព នាយកដ្ឋាននីតិកម្ម |
| ៣២-ឧត្តមសេនីយ៍ត្រី | សំ ស៊ីន | អត្តលេខ០១០២០៧ | កងឯកភាព អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស |
| ៣៣-ឧត្តមសេនីយ៍ត្រី | ប៊ុន វណ្ណៈ | អត្តលេខ០២១១៩៦ | កងឯកភាព នាយកដ្ឋានអភិវឌ្ឍន៍ |
| ៣៤-ឧត្តមសេនីយ៍ត្រី | ជៀម នីតា | អត្តលេខ១៥១៨៤៨ | កងឯកភាព នាយកដ្ឋានអភិវឌ្ឍន៍ |
| ៣៥-ឧត្តមសេនីយ៍ត្រី | ម៉ែន ទូច | អត្តលេខ០២៣៨៥០ | កងឯកភាព អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ |
| ៣៦-ឧត្តមសេនីយ៍ត្រី | ណារ៉ាវ សុភឿន | អត្តលេខ០១៥៣៧៣ | កងឯកភាព អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ |
| ៣៧-ឧត្តមសេនីយ៍ត្រី | ជ័យ សាលី | អត្តលេខ០២២២៦៩ | កងឯកភាព នាយកដ្ឋានអធិការកិច្ច |
| ៣៨-ឧត្តមសេនីយ៍ត្រី | តាន់ សុខារិទ្ធ | អត្តលេខ០១៤១៣៣ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ៣៩-ឧត្តមសេនីយ៍ត្រី | ជុំ សុជាតិ | អត្តលេខ០០៣២០២ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ៤០-ឧត្តមសេនីយ៍ត្រី | អ៊ុន សារី | អត្តលេខ០៣១៥៧៦ | កងឯកភាព នាយកដ្ឋានព័ត៌មាន |
| ៤១-ឧត្តមសេនីយ៍ត្រី | មាស ម៉មឫទ្ធី | អត្តលេខ០២២២១៤ | កងឯកភាព នាយកដ្ឋានអភិវឌ្ឍន៍ |
| ៤២-ឧត្តមសេនីយ៍ត្រី | ចាន់ ប៊ុណ្ណារ៉ាវឿន | អត្តលេខ០៤៨១៧៣ | កងឯកភាព នាយកដ្ឋានបុគ្គលិក |
| ៤៣-ឧត្តមសេនីយ៍ត្រី | រី ចំរើន | អត្តលេខ១៥៨៦៦៨ | កងឯកភាព កងពលតូចដឹកជញ្ជូនលេខ៩៩ |
| ៤៤-ឧត្តមសេនីយ៍ត្រី | រស់ ស៊ុនហេង | អត្តលេខ០១៤០២៩ | កងឯកភាព នាយកដ្ឋានអធិការកិច្ច |
| ៤៥-ឧត្តមសេនីយ៍ត្រី | នាង ម៉ៅ | អត្តលេខ០២៥២៣៣ | កងឯកភាព នាយកដ្ឋានប្រេងឥន្ធនៈ |
| ៤៦-ឧត្តមសេនីយ៍ត្រី | វ័ន្ត សុគន្ធទូច | អត្តលេខ១០៥០៣១ | កងឯកភាព មជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ |
| ៤៧-ឧត្តមសេនីយ៍ត្រី | ថាក់ គុណឆាង | អត្តលេខ១៨៨២០១ | កងឯកភាព នាយកដ្ឋានកិច្ចការយោធា ស៊ីវិល |
| ៤៨-ឧត្តមសេនីយ៍ត្រី | យ៉ែន សេរីយ៉ា | អត្តលេខ០៥៨៤៩៤ | កងឯកភាព នាយកដ្ឋានកិច្ចការយោធា ស៊ីវិល |
| ៤៩-ឧត្តមសេនីយ៍ត្រី | ចាន់ សាន | អត្តលេខ០២៥១៥៥ | កងឯកភាព នាយកដ្ឋានវិស្វកម្ម |
| ៥០-ឧត្តមសេនីយ៍ត្រី | នេន វីរ៉ាន | អត្តលេខ០៣១៧៥៩ | កងឯកភាព អគ្គនាយកដ្ឋានយោធសេវា |
| ៥១-វរសេនីយ៍ឯក | ហ៊ី ហាន | អត្តលេខ០១៧៩៥៨ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាពយោធិនពិការ៣១៧ កោះស្លា |
| ៥២-វរសេនីយ៍ឯក | មិន ម៉ៅ | អត្តលេខ០៣៦៨៥៤ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាពយោធិនពិការ៣១៧ កោះស្លា |

| | | | |
|---|---|---|---|
| ៥៣-វរសេនីយ៍ឯក | មាន សារម៉េន | អត្តលេខ០៣៦៨០៨ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៥៤-វរសេនីយ៍ឯក | គង់ ណារុន | អត្តលេខ០២០៣២២ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៥៥-វរសេនីយ៍ឯក | យឿន សារឿន | អត្តលេខ០៣៣៧៧៩ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៥៦-វរសេនីយ៍ឯក | ហ៊ុន ម៉ាន្នី | អត្តលេខ០៣៦៨៥៨ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៥៧-វរសេនីយ៍ឯក | ម៉ាត់ គាព | អត្តលេខ០៣៦៨៥២ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៥៨-វរសេនីយ៍ឯក | សួស សុគន្ធ | អត្តលេខ០២៥៥២១ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៥៩-វរសេនីយ៍ឯក | សុខ យឹម | អត្តលេខ០៤១៨៨០ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៦០-វរសេនីយ៍ឯក | ពេជ្រ រដ្ឋា | អត្តលេខ០៣៦៨០៦ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៦១-វរសេនីយ៍ឯក | មាស សេរីវុធ | អត្តលេខ០៤០៨៤៨ | កងឯកភាព មជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ៣១៧ កោះស្លា |
| ៦២-វរសេនីយ៍ឯក | មាស រដ្ឋា | អត្តលេខ០៤៨១១៤ | កងឯកភាព នាយកដ្ឋានសោធននិវត្តន៍ |
| ៦៣-វរសេនីយ៍ឯក | អ៊ាន់ ម៉េងឌុន | អត្តលេខ១៨៧១៨៣ | កងឯកភាព នាយកដ្ឋានអភិវឌ្ឍន៍ |
| ៦៤-វរសេនីយ៍ឯក | គិន សុផល | អត្តលេខ០១៦៨០០ | កងឯកភាព នាយកដ្ឋានអប់រំ |
| ៦៥-វរសេនីយ៍ឯក | លី ប៊ុនសេង | អត្តលេខ០៤២៩៥៦ | កងឯកភាព នាយកដ្ឋានផ្គត់ផ្គង់ |
| ៦៦-វរសេនីយ៍ឯក | គិន តារិទ្ធ | អត្តលេខ១៩៨២៥៦ | កងឯកភាព អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស |
| ៦៧-វរសេនីយ៍ឯក | ឯម សាគុណ | អត្តលេខ០១៣៩៤៧ | កងឯកភាព អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស |
| ៦៨-វរសេនីយ៍ឯក | កែវ ស៊ីថា | អត្តលេខ០៤៣០៩៩ | កងឯកភាព នាយកដ្ឋានយន្តយុទ្ធ |
| ៦៩-វរសេនីយ៍ឯក | កែវ ឈិន | អត្តលេខ០៣១៦៣៨ | កងឯកភាព នាយកដ្ឋានកិច្ចការយោធា ស៊ីវិល |
| ៧០-វរសេនីយ៍ឯក | ស្រី វាសនា | អត្តលេខ២២១៧៩៤ | កងឯកភាព មជ្ឈមណ្ឌលជាតិគ្រប់គ្រង |

កងកម្លាំងរក្សាសន្តិភាពបោសសំអាតមីន និងកាកសំណល់សង្គ្រាម

៧១-វរសេនីយ៍ឯក **ខ្មៅ ដានី** អត្តលេខ១៩៦១៨៥៩ កងឯកភាព នាយកដ្ឋានបច្ចេកទេស កងទ័ពជើងទឹក

៧២-វរសេនីយ៍ឯក **អ៊ិត សិលា** អត្តលេខ២០០៩៩៥ កងឯកភាព មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសំអាតមីន និងកាកសំណល់សង្គ្រាម

**មាត្រា២.** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០២៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៣៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរយោធិនពលី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១:** ផ្ទេរយោធិនពលី នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម៖

១-ឧត្តមសេនីយ៍ឯក **នៅ សាវ៉ន** អត្តលេខ០០៣៧៧៦ កងឯកភាព បញ្ជាការដ្ឋានអង្គរក្ស

២-ឧត្តមសេនីយ៍ឯក **ប្រុញ សត្ថម៉ា** អត្តលេខ០០៤០៣៣ កងឯកភាព បញ្ជាការដ្ឋានអង្គរក្ស

| | | | |
|---|---|---|---|
| ៣-ឧត្តមសេនីយ៍ទោ | **ឃួន សុវណ្ណា** | អត្តលេខ០១០៥០៥ | កងឯកភាព តំបន់ប្រតិបត្តិការសឹករងកែប |
| ៤-ឧត្តមសេនីយ៍ទោ | **សយ អ៊ិត** | អត្តលេខ០០៨៥៣៥ | កងឯកភាព នាយកដ្ឋានសុខាភិបាល |
| ៥-ឧត្តមសេនីយ៍ទោ | **សុខ នឿន** | អត្តលេខ០០៤១៦៤ | កងឯកភាព បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន |
| ៦-ឧត្តមសេនីយ៍ទោ | **គង់ ធី** | អត្តលេខ០០៩៤០៣ | កងឯកភាព បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន |
| ៧-ឧត្តមសេនីយ៍ត្រី | **អោម សុខេន** | អត្តលេខ០១៥៤៧២ | កងឯកភាព តំបន់ប្រតិបត្តិការសឹករង កំពង់ស្ពឺ |
| ៨-ឧត្តមសេនីយ៍ត្រី | **អ៊ុំ សាវុន** | អត្តលេខ០០៥១១១ | កងឯកភាព កងពលតូចអន្តរាគមន៍លេខ១៤ |
| ៩-ឧត្តមសេនីយ៍ត្រី | **ជួប ឡុច** | អត្តលេខ០០៥១០៩ | កងឯកភាព យោធភូមិភាគទី៥ |
| ១០-ឧត្តមសេនីយ៍ត្រី | **ប្រាក់ ផាន** | អត្តលេខ០០៣៩៦៤ | កងឯកភាព យោធភូមិភាគទី៥ |
| ១១-វរសេនីយ៍ឯក | **អ៊ុំ ប៊ូរ៉ានីណូ** | អត្តលេខ២៣១៧៣៩ | កងឯកភាព មជ្ឈមណ្ឌលកីឡាកងយោធពល ខេមរភូមិន្ទ |
| ១២-វរសេនីយ៍ឯក | **ហ៊ុល ម៉ាន់ណៃ** | អត្តលេខ០១៤៧៧២ | កងឯកភាព នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន |
| ១៣-វរសេនីយ៍ឯក | **សួន សុឃឿន** | អត្តលេខ០៣៩៧៣៤ | កងឯកភាព បញ្ជាការដ្ឋានរថក្រោះ អគ្គបញ្ជាការដ្ឋាន |
| ១៤-វរសេនីយ៍ឯក | **គា គីម** | អត្តលេខ០៩០០៩៦ | កងឯកភាព យោធភូមិភាគទី៥ |
| ១៥-វរសេនីយ៍ឯក | **ម៉ៃ យីមហ៊ាន** | អត្តលេខ០៣១៥១៨ | កងឯកភាព យោធភូមិភាគទី៥ |
| ១៦-វរសេនីយ៍ឯក | **ទេព ម៉ុនថន** | អត្តលេខ០៧៣៣៧៤ | កងឯកភាព យោធភូមិភាគទី៥ |
| ១៧-វរសេនីយ៍ឯក | **ស្រី លីម** | អត្តលេខ០១១៩០៧ | កងឯកភាព យោធភូមិភាគទី៥ |
| ១៨-វរសេនីយ៍ឯក | **គង់ សំអុល** | អត្តលេខ០០៥១៣៥ | កងឯកភាព យោធភូមិភាគទី៥ |
| ១៩-វរសេនីយ៍ឯក | **កែវ ណារិន** | អត្តលេខ០១៩៩៧៧ | កងឯកភាព យោធភូមិភាគទី៥ |
| ២០-វរសេនីយ៍ឯក | **នី ធី** | អត្តលេខ០៣០៨៣១ | កងឯកភាព យោធភូមិភាគទី៥ |
| ២១-វរសេនីយ៍ឯក | **យ៉ាន យឿប** | អត្តលេខ០២៣០៤៦ | កងឯកភាព យោធភូមិភាគទី៥ |

២២-វរសេនីយ៍ឯក គង់ ស៊ិន អត្តលេខ០៤១៤៦៥ កងឯកភាព យោធភូមិភាគទី៥

**មាត្រា២:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០២៣* ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៤០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ម៉ម ទិទ្ធិភា** អត្តលេខ ៦៥២១៩ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៨២.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែង នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨ /៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** តែងតាំងមុខតំណែង នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-ឧត្តមសេនីយ៍ទោ **ស៊ីន សម្បត្តិ** អត្តលេខ ០៣៦២២៥ ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

២-ឧត្តមសេនីយ៍ត្រី **សោម ផាន្នី** អត្តលេខ ០១៤៤៤៣ ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១២ កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៨៣ អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

**ការតែងតាំងមុខតំណែង នាយទាហាន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** តែងតាំងមុខតំណែង នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន ឧត្តមសេនីយ៍ទោ **ទេពចំរើន សាមីឌី** អត្តលេខ ០២៥១៣៧ ជា នាយក នាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ១២ កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.**_បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន២០៦រូប ខេត្តកំពង់ស្ពឺ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ប៊ិច ចំរើន | ប្រធានការិយាល័យសាលាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ |
| ២- | លោកស្រី | ខឹម ស៊ីណាន | អនុប្រធានការិយាល័យសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៣- | លោក | ផាត សុភ័ក្រ | ប្រធានការិយាល័យសាលាខេត្តកំពង់ស្ពឺ |
| ៤- | លោក | ភួង ប៊ុណ្ណាក់ | អនុប្រធានការិយាល័យសាលាក្រុងច្បារមន ខេត្តកំពង់ស្ពឺ |
| ៥- | លោក | ស៊ុំ លន | មន្ត្រីសាលាក្រុងច្បារមន ខេត្តកំពង់ស្ពឺ |

| | | | |
|---|---|---|---|
| ៦- | លោក | ឈួន យ៉េត | នាយករងរដ្ឋបាលសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ៧- | លោកស្រី | ហុក ស៊ីថា | អនុប្រធានការិយាល័យសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ៨- | លោក | ម៉ម កុសល | ប្រធានអង្គភាពលទ្ធកម្មសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ៩- | លោកស្រី | សួស សុម៉ាលី | ប្រធានការិយាល័យសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១០- | លោកស្រី | កែវ សុជាតិ | ប្រធានការិយាល័យច្រកចេញចូលតែមួយសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១១- | លោក | ហ៊ុន សិទ្ធត្រា | ប្រធានការិយាល័យសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១២- | លោកស្រី | ខឹម កញ្ញា | មន្ត្រីការិយាល័យច្រកចេញចូលតែមួយសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១៣- | លោកស្រី | សៀក សុខកល | ប្រធានការិយាល័យសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១៤- | លោក | មុំ សំនិត | ប្រធានការិយាល័យសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១៥- | លោក | ចាន់ វុត្ថា | នាយករងរដ្ឋបាលសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ១៦- | លោក | អ៊ួន គឹមស្រ៊ីម | ប្រធានការិយាល័យច្រកចេញចូលតែមួយសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ១៧- | លោកស្រី | សុខ ខានិត | អនុប្រធានការិយាល័យសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ១៨- | លោក | ចិន សុខគា | អនុប្រធានអង្គភាពលទ្ធកម្មសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ១៩- | លោក | កែវ បូរី | ប្រធានការិយាល័យសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ២០- | លោក | យ៉ុង សុខយ៉េន | ប្រធានការិយាល័យសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ២១- | លោកស្រី | មៀច សុចិន្តា | អនុប្រធានការិយាល័យសាលាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ |
| ២២- | លោកស្រី | ម៉ុម រតនា | នាយករងរដ្ឋបាលសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ |
| ២៣- | លោកស្រី | ស៊ុន សុទ្ធី | អនុប្រធានការិយាល័យសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ |
| ២៤- | លោក | ហៃ សម្ផស្ស | មន្ត្រីសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ |
| ២៥- | លោក | ប្រាក់ សុខេម | មន្ត្រីសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ |
| ២៦- | លោកស្រី | ទេព អួងសោភា | ប្រធានការិយាល័យសាលាខេត្តកំពង់ស្ពឺ |
| ២៧- | លោក | ព្រហ្ម សាម៉េត | មន្ត្រីសាលាខេត្តកំពង់ស្ពឺ |
| ២៨- | លោក | សុខ សុខា | ប្រធានការិយាល័យសាលាស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ |
| ២៩- | លោក | ឃួន ហោ | អនុប្រធានការិយាល័យសាលាស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ |

ខ-មេដាយ**ប្រាក់អាវរងារ**

| | | | |
|---|---|---|---|
| ១- | លោកស្រី | កែវ កក្កដា | មន្ត្រីការិយាល័យច្រកចេញចូលតែមួយសាលាខេត្តកំពង់ស្ពឺ |
| ២- | លោក | សុផល បញ្ញា | មន្ត្រីសាលាខេត្តកំពង់ស្ពឺ |
| ៣- | លោក | ផេន សុផាត | នាយករងរដ្ឋបាលសាលាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ |
| ៤- | លោកស្រី | ប៉ាញ ចែម | អនុប្រធានការិយាល័យសាលាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ |
| ៥- | លោកស្រី | តេ ពិសី | អនុប្រធានការិយាល័យច្រកចេញចូលតែមួយសាលាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ |
| ៦- | លោក | ទ្រី សុខា | នាយករដ្ឋបាលសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៧- | លោក | អ៊ុង សំអាន | នាយករងរដ្ឋបាលសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៨- | លោក | ចាន់ លឹមសេង | នាយករងរដ្ឋបាលសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៩- | លោកស្រី | សៀង សុក | ប្រធានការិយាល័យសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ១០- | លោកស្រី | ចន សារ៉ា | ប្រធានការិយាល័យសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ១១- | លោក | ឈាង ប៊ុនហាក់ | ប្រធានការិយាល័យសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **ឈឺន សុធន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ពីអភិបាល នៃគណៈអភិបាលស្រុកបសេដ្ឋ ឱ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តកំពង់ស្ពឺ។

**មាត្រា ២ :** តែងតាំងលោក **សំអឿន សុបញ្ញា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ជាអភិបាល នៃគណៈអភិបាលស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible]......សហវ.[illegible]

## ប្រកាស
## ស្តីពី
## ការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្មសម្រាប់មុខចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួលរថយន្ត សម្រាប់រដ្ឋបាលថ្នាក់ជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៥៤៤ សហវ.ប្រក. ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះ កំណត់អំពីនីតិវិធីអនុវត្តកិច្ចព្រមព្រៀងសាជីវកម្មលើមុខសញ្ញាចំណាយជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួលសជុលរថយន្ត ក្នុងគោលដៅសម្រួលនីតិវិធីអនុវត្តចំណាយថវិកានៃមុខសញ្ញាចំណាយទាំងនេះ ដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ភាពទាន់ពេល មានតម្លាភាព និងគណនេយ្យភាព។

**ប្រការ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ សម្រាប់ការចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយអ្នកផ្តល់សេវាកម្មឯកជន លើមុខសញ្ញាចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលានិងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត។

**ប្រការ៣._**

កិច្ចព្រមព្រៀងសាជីវកម្ម សំដៅដល់ទម្រង់នៃការចុះកិច្ចសន្យារវាង ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ជាមួយនឹងអ្នកផ្តល់សេវាកម្ម ដើម្បីទទួលបាននូវសេវាកម្ម ប្រកបដោយគុណភាព និងទាន់ពេលវេលាតាមតម្រូវការប្រើប្រាស់។

## ជំពូកទី២

## គោលការណ៍រួម នីតិវិធីនៃការចុះកិច្ចព្រមព្រៀងសាជីវកម្ម និងការអនុវត្តចំណាយ

### ផ្នែកទី ១

### គោលការណ៍រួម

**ប្រការ៤._**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ដែលមានតម្រូវការប្រើប្រាស់សេវារបស់អ្នកផ្តល់សេវាកម្មឯកជន ត្រូវចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយអ្នកផ្តល់សេវាកម្ម សម្រាប់មុខសញ្ញាចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត។ ដោយឡែក ក្នុងករណី ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ប្រើប្រាស់ទីតាំងអង្គភាពរដ្ឋ គឺមិនតម្រូវឱ្យចុះកិច្ចព្រមព្រៀងសាជីវកម្មទេ។

**ប្រការ៥._**

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ត្រូវរៀបចំកិច្ចព្រមព្រៀងសាជីវកម្មសម្រាប់អនុវត្តនៅគ្រប់អង្គភាពថវិកាថ្នាក់កណ្តាល ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ពិនិត្យ និងចុះហត្ថលេខាជាមួយនឹងអ្នកផ្តល់សេវាកម្ម។ ក្រសួង ស្ថាប័ន ត្រូវចម្លងកិច្ចព្រមព្រៀងសាជីវកម្មនេះ ជូនគ្រប់អង្គភាពថវិកាដើម្បីអនុវត្ត។ ដោយឡែកអង្គភាពថវិកាដែលជាមន្ទីរជំនាញរាជធានី ខេត្តក្រោមឱវាទ ត្រូវបានអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយអ្នកផ្តល់សេវាកម្មដោយផ្ទាល់។

**ប្រការ៦._**

សុពលភាពនៃកិច្ចព្រមព្រៀងសាជីវកម្ម ត្រូវមានរយៈពេលមួយលើកៗមិនលើសពី ២ (ពីរ)ឆ្នាំ។

**ប្រការ៧.-**

មុខសញ្ញាចំណាយដែលត្រូវចុះកិច្ចព្រមព្រៀងសាជីវកម្មរវាងក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ជាមួយនឹងអ្នកផ្តល់សេវាកម្ម ត្រូវគ្របដណ្តប់តែលើចំណាយដែលពាក់ព័ន្ធនឹងការជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត។ ចំណាយទាំងនេះត្រូវផ្អែកលើគោលការណ៍សន្សំសំចៃ តម្លៃសមស្រប ព្រមទាំងត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៨.-**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវរៀបចំគម្រោងចំណាយឱ្យបានច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ លើមុខចំណាយពាក់ព័ន្ធនឹងការជួលទីតាំង សម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ជៀសវាងចំណាយបន្ថែមក្រៅគម្រោងនៅពេលអនុវត្តជាក់ស្តែង។

**ប្រការ៩.-**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយអ្នកផ្តល់សេវាកម្មសម្រាប់មុខសញ្ញាចំណាយនីមួយៗយ៉ាងតិច ២(ពីរ) ក្នុងរាជធានី និងខេត្តនីមួយៗដែលមានតម្រូវការអនុវត្តមុខសញ្ញាចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត។

**ប្រការ១០.-**

កិច្ចព្រមព្រៀងសាជីវកម្មរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវឆ្លងកាត់ការត្រួតពិនិត្យនិងផ្តល់ការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មុននឹងមានសុពលភាពអនុវត្ត។ ចំពោះកិច្ចព្រមព្រៀងសាជីវកម្មរបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវឆ្លងកាត់ការត្រួតពិនិត្យនិងផ្តល់ការទទួលស្គាល់ពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត មុននឹងមានសុពលភាពអនុវត្ត។ រីឯកិច្ចព្រមព្រៀងសាជីវកម្មរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវឆ្លងកាត់ការត្រួតពិនិត្យនិងផ្តល់ការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មុននឹងមានសុពលភាពអនុវត្ត។

**ប្រការ១១.-**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយអ្នកផ្តល់សេវាកម្មតាមគំរូកិច្ចព្រមព្រៀងសាជីវកម្មដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ រួចត្រូវផ្ញើកិច្ចព្រមព្រៀងសាជីវកម្មដែលបានចុះហត្ថលេខាហើយមកអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមប្រការ៩ ខាងលើ ដើម្បីពិនិត្យអនុលោមភាពនៃកិច្ចព្រមព្រៀងសាជីវកម្មជាមួយនឹងលក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ និងចុះហត្ថលេខាផ្តល់ការមិនយល់ទាស់លើកិច្ចព្រមព្រៀងសាជីវកម្ម។

**ប្រការ១២._**

អ្នកផ្តល់សេវាកម្មដែលបានចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ លើមុខសញ្ញាចំណាយជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួលជុលរថយន្ត ត្រូវមានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ និងអាករគ្រប់ប្រភេទ រួមទាំងអាករលើតម្លៃបន្ថែម តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ផ្នែកទី ២
## នីតិវិធីនៃការចុះកិច្ចព្រមព្រៀងសាជីវកម្ម
### ក. ការជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ

**ប្រការ១៣._**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវពិនិត្យលទ្ធភាពក្នុងការចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយសណ្ឋាគារ ឬទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ និង/ឬតាមបណ្តាខេត្ត តាមតម្រូវការជាក់ស្តែង។ សណ្ឋាគារ ឬទីតាំងដែលមានសិទ្ធិចុះកិច្ចព្រមព្រៀងសាជីវកម្ម ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម÷

- មានអាជ្ញាបណ្ណទេសចរណ៍ដែលមានចំណាត់ថ្នាក់ទាបបំផុតកម្រិតផ្កាយ៣ ចេញដោយក្រសួងទេសចរណ៍ ឬកម្រិតប្រហាក់ប្រហែល
- មានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម
- មានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ចេញដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានប័ណ្ណពន្ធប៉ាតង់ (ឆ្នាំចុះកិច្ចព្រមព្រៀងសាជីវកម្ម) ចេញដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានសម្ភារឧបករណ៍គ្រប់គ្រាន់សម្រាប់ទទួលបដិសណ្ឋារកិច្ចរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ
- មានបទពិសោធន៍យ៉ាងតិច ១(មួយ)ឆ្នាំ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ។

**ប្រការ ១៤._**

តម្លៃនៃការជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវអនុលោមតាមប្រកាសលេខ ១០២ សហវ.ប្រក

ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីរបៀបនិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ចំពោះតម្លៃនៃការជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់សហគ្រាសសាធារណៈ ត្រូវផ្អែកលើគោលការណ៍សន្សំសំចៃ និងតម្លៃសមស្រប។

## ខ. ការទិញសំបុត្រយន្តហោះ

**ប្រការ១៥._**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវចុះកិច្ចព្រមព្រៀងសាជីវកម្មទិញសំបុត្រយន្តហោះជាមួយក្រុមហ៊ុនអាកាសចរណ៍/ការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ឬនៅតាមបណ្តាខេត្ត តាមតម្រូវការជាក់ស្តែង។ ក្រុមហ៊ុនអាកាសចរណ៍/ការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍ដែលមានសិទ្ធិចុះកិច្ចព្រមព្រៀងសាជីវកម្ម ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានអាជ្ញាបណ្ណប្រតិបត្តិការ ចេញដោយក្រសួងទេសចរណ៍/រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- មានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម
- មានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ចេញដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានប័ណ្ណពន្ធប៉ាតង់ (ឆ្នាំចុះកិច្ចព្រមព្រៀងសាជីវកម្ម) ចេញដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានទីតាំងប្រកបអាជីវកម្មត្រឹមត្រូវច្បាស់លាស់ និងមានកេរ្តិ៍ឈ្មោះល្អនៅក្នុងអាជីវកម្មពាក់ព័ន្ធ
- មានបទពិសោធន៍ប្រកបអាជីវកម្មលក់សំបុត្រយន្តហោះយ៉ាងតិច ១(មួយ)ឆ្នាំ សម្រាប់ការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍ និងយ៉ាងតិច ៣(បី)ឆ្នាំ សម្រាប់ក្រុមហ៊ុនអាកាសចរណ៍។

**ប្រការ១៦._**

តម្លៃទិញសំបុត្រយន្តហោះ ត្រូវឈរលើគោលការណ៍សន្សំសំចៃ និងតម្លៃសមស្រប ដោយយោងតាមលក្ខខណ្ឌជាក់ស្តែងមានជាអាទិ៍៖ ក្រុមហ៊ុនអាកាសចរណ៍ ប្រភេទសំបុត្រ ចំនួនសំបុត្រ គោលដៅហោះហើរ គម្លាតពេលវេលាថ្ងៃទិញសំបុត្រ និងរដូវកាលហោះហើរ។

## គ. ការជួលជុលរថយន្ត

**ប្រការ១៧._**

ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយក្រុមហ៊ុន/យានដ្ឋានជួសជុលរថយន្តនៅក្នុងរាជធានីភ្នំពេញ និង/ឬ

នៅតាមបណ្តាខេត្ត តាមតម្រូវការជាក់ស្តែង។ ក្រុមហ៊ុន/ យានដ្ឋានជួសជុលរថយន្តដែលមានសិទ្ធិចុះកិច្ចព្រមព្រៀងសាជីវកម្ម ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម÷

- មានវិញ្ញាបនប័ត្រចុះបញ្ជីយានដ្ឋានចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន/មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
- មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន/មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
- មានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ចេញដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានប័ណ្ណពន្ធប៉ាតង់ (ឆ្នាំចុះកិច្ចព្រមព្រៀងសាជីវកម្ម) ចេញដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានទីតាំងប្រកបអាជីវកម្មត្រឹមត្រូវច្បាស់លាស់
- មានសម្ភារឧបករណ៍គ្រប់គ្រាន់សម្រាប់ជួសជុលរថយន្ត
- មានបទពិសោធន៍ជួសជុលរថយន្តយ៉ាងតិច ១(មួយ)ឆ្នាំ។

**ប្រការ១៨._**

តម្លៃជួសជុលរថយន្ត ត្រូវផ្អែកលើគោលការណ៍សន្សំសំចៃ និងតម្លៃសមស្រប ព្រមទាំងធ្វើការប្រៀបធៀបតម្លៃជាមួយក្រុមហ៊ុន/ យានដ្ឋានជួសជុលរថយន្តផ្សេងទៀត។

## ផ្នែកទី៣
## នីតិវិធីនៃការអនុវត្តចំណាយ

**ប្រការ១៩._**

រាល់មុខសញ្ញាចំណាយដែលបានចុះកិច្ចព្រមព្រៀងសាជីវកម្ម មិនតម្រូវឱ្យមានការស្នើសុំធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទេ។ ចំពោះមុខសញ្ញាចំណាយដែលមិនបានចុះកិច្ចព្រមព្រៀងសាជីវកម្ម ឬមុខសញ្ញាចំណាយដែលមានតម្រូវការលើសគោលរបបដែលមានចែងក្នុងប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ២០._**

នីតិវិធីនៃការអនុវត្ត និងការទូទាត់ចំណាយជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ចំពោះក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវអនុវត្តតាមប្រកាសលេខ ១០២ សហវ.ប្រក

ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីរបិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ដោយឡែក ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។ ក្នុងករណីអនុវត្តតាមនីតិវិធីទូទាត់ត្រង់ ការទូទាត់ត្រូវធ្វើឡើងដោយបង្វែរចូលគណនីរបស់សណ្ឋាគារឬម្ចាស់ទីតាំង។

**ប្រការ២១._**

ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ស្នើសុំទូទាត់ចំណាយទិញសំបុត្រយន្តហោះតាមវិក្កយបត្រជាក់ស្តែងរបស់ក្រុមហ៊ុនអាកាសចរណ៍/ការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវស្របតាមលក្ខខណ្ឌដែលមាននៅក្នុងកិច្ចព្រមព្រៀងសាជីវកម្មដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២២._**

ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ទូទាត់ថ្លៃជួលជុលរថយន្តតាមវិក្កយបត្រជាក់ស្តែង មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសាជីវកម្មដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។ ដោយឡែក ចំពោះការជួសជុលរថយន្តដែលកើតឡើងនៅទីតាំងដែលមិនមានចុះកិច្ចព្រមព្រៀងសាជីវកម្មជាមួយអ្នកផ្តល់សេវាជួសជុល ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ២៣._**

នីតិវិធីនៃការអនុវត្ត និងការទូទាត់ចំណាយរបស់សហគ្រាសសាធារណៈ សម្រាប់ការជួលទីតាំងដើម្បីរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ ការទិញសំបុត្រយន្តហោះ និងការជួសជុលរថយន្ត ត្រូវអនុវត្តតាមនីតិវិធីដោយឡែកសម្រាប់សហគ្រាសសាធារណៈដែលមានជាធរមាន។

**ប្រការ២៤._**

គំរូទម្រង់កិច្ចព្រមព្រៀងសាជីវកម្មសម្រាប់មុខសញ្ញាចំណាយរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងសិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត រវាងក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ ជាមួយនឹងអ្នកផ្តល់សេវាកម្ម មានភ្ជាប់ជូនជាឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ២៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៦._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៧រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ មីនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- សហគ្រាសសាធារណៈ
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ដូចក្នុងប្រការ២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ១**

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ១៥១ សហវ.ប្រក.អលសា ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្ម សម្រាប់ មុខចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងសិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត សម្រាប់រដ្ឋបាលថ្នាក់ជាតិ)

## កិច្ចព្រមព្រៀងសាជីវកម្មស្តីពីការជួលទីតាំង សម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទ

**រវាង**

- **ក្រសួង/ស្ថាប័ន/សហគ្រាសសាធារណៈ/គ្រឹះស្ថានសាធារណៈរដ្ឋបាល/អង្គភាពសាធារណៈប្រហាក់ប្រហែល/អង្គភាពថវិកា** .................... តំណាងដោយ ........................... មុខងារ...................... មានអាសយដ្ឋាន ......................... ......................... ហៅកាត់ថាភាគី “**ក**”

**និង**

- **សណ្ឋាគារ/ម្ចាស់ទីតាំង**........................................... តំណាងដោយ.......................... មុខងារ.................. មានអាសយដ្ឋាន ................................................ ហៅកាត់ថាភាគី “**ខ**” ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ÷**

**ប្រការ១- អំពីគោលការណ៍**

ភាគី “ក” និងភាគី “ខ” យល់ព្រមប្រើប្រាស់ និងផ្តល់សេវាកម្មជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទ សម្រាប់រយៈពេល ..... (  )ឆ្នាំ ចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ......ដល់ថ្ងៃទី.....ខែ.....ឆ្នាំ......។

**ប្រការ២- តម្លៃជួលទីតាំង**

តម្លៃជួលទីតាំងសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទ ត្រូវមានតម្លៃទាបសមស្រប ធៀបជាមួយតម្លៃធម្មតា(តម្លៃមិនមានការចុះកិច្ចព្រមព្រៀងសាជីវកម្ម) និងប្រែប្រួលទៅតាម (១).ចំនួនអ្នកដែលនឹងចូលរួម វគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទ (២).រយៈពេលនៃការជួល (៣).កញ្ចប់សេវាកម្មពាក់ព័ន្ធដូចជា សម្ភារបរិក្ខារ អាហារសម្រន់ អាហារថ្ងៃត្រង់ និង/ឬអាហារពេលល្ងាច។

តម្លៃជួលទីតាំងសរុបជាក់ស្តែងមួយលើកៗ ត្រូវផ្អែកតាមតារាងតម្លៃជួលទីតាំងដូចមានចែងក្នុងប្រការ៣ នៃកិច្ចព្រមព្រៀងសាជីវកម្មនេះ និងត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរ។

**ប្រការ៣- ភារកិច្ចរបស់គូភាគី**

ភាគី “ខ” ត្រូវផ្តល់ជូនភាគី “ក” នូវតារាងតម្លៃជួលទីតាំងប្រចាំត្រីមាសនៅរៀងរាល់ដើមត្រីមាសនីមួយៗ។

ភាគី “ក” ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរពីការជួលទីតាំងទៅភាគី “ខ” យ៉ាងតិច ៣(បី)សប្តាហ៍ មុនកាលបរិច្ឆេទនៃតម្រូវការជួលទីតាំងមួយលើកៗដោយបញ្ជាក់ជាបឋមអំពី÷ (១).ប្រភេទនៃការប្រជុំ (២).ចំនួនអ្នកចូលរួម, (៣).រយៈពេលនៃការជួល និង (៤).កញ្ចប់សេវាកម្មពាក់ព័ន្ធដូចជា សម្ភារបរិក្ខារ អាហារសម្រន់ អាហារថ្ងៃត្រង់ និង/ឬអាហារពេលល្ងាច។

ក្នុងករណីភាគី “ក” ជូនដំណឹងអំពីការជួលទីតាំង តិចជាងការកំណត់ខាងលើ ហើយភាគី “ខ” អាចចាត់ចែងរៀបចំទីតាំងជួលបានទាន់ពេលវេលា នោះភាគី “ខ” ត្រូវផ្តល់សេវាកម្មតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងសាជីវកម្មនេះ។

ភាគី “ខ” ត្រូវចេញវិក្កយបត្របណ្តោះអាសន្ន (Quotation) ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីតម្លៃជួលទីតាំងសរុប ដោយត្រូវរំលេចមុខចំណាយនិងការផ្តល់បន្ថែមនូវអត្ថប្រយោជន៍ផ្សេងៗដោយមិនគិតថ្លៃជូនភាគី “ក” (មានដូចជា Backdrop, LCD, Flowers, Welcome banner, ជាដើម)។

នៅរយៈពេលយ៉ាងតិច ៥(ប្រាំ)ថ្ងៃ មុនកាលបរិច្ឆេទវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទចាប់ផ្តើមដំណើរការភាគី “ក” ត្រូវបញ្ជាក់បន្ថែមជូនភាគី “ខ” ឱ្យបានច្បាស់ឡើងវិញនូវករណីខាងលើ ដើម្បីបង្កភាពងាយស្រួលដល់ភាគី “ខ” ត្រៀមការផ្តល់សេវាកម្មជូនភាគី “ក” ឱ្យបានល្អនិងគ្រប់ជ្រុងជ្រោយ។

**ប្រការ៤- ការទូទាត់**

ភាគី “ខ” ត្រូវបូកសរុបប្រចាំខែនូវតម្លៃជួលទីតាំងពីភាគី “ក” ដើម្បីរៀបចំវិក្កយបត្ររួចផ្ញើមកភាគី “ក” ដើម្បីធ្វើការទូទាត់។ ការទូទាត់ត្រូវធ្វើឡើងមិនឱ្យលើស ៣០(សាមសិប)ថ្ងៃ ក្រោយកាលបរិច្ឆេទទទួលវិក្កយបត្រ ដោយត្រូវបង្វែរចូលគណនីរបស់សណ្ឋាគារឬម្ចាស់ទីតាំង។

**ប្រការ៥- ពន្ធ អាករ**

ភាគី “ខ” មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធអាករគ្រប់ប្រភេទ រួមទាំង “អាករលើតម្លៃបន្ថែម” តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៦- ការកែប្រែការជួលទីតាំង**

ប្រសិនបើភាគី “ក” មានតម្រូវការចាំបាច់ក្នុងការផ្លាស់ប្តូរឬលើកកាលបរិច្ឆេទ រៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលាកិច្ចប្រជុំ និងសន្និសីទ នោះភាគី “ក” ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគី “ខ” ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃមុនកាលបរិច្ឆេទនៃតម្រូវការជួលទីតាំងមួយលើកៗ និងត្រូវពិភាក្សាស្វែងរកដំណោះស្រាយលើការកែប្រែនោះ។

**ប្រការ៧- ការផាកពិន័យ**

ក្នុងករណីមិនបានបំពេញកាតព្វកិច្ចក្នុងការរៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទ បានតាមកាលបរិច្ឆេទកំណត់ ដែលបណ្តាលមកពីភាគី “ខ” នោះភាគី “ខ” ត្រូវទទួលរងនូវការផាកពិន័យចំនួន ២០% នៃតម្លៃជួល

ទីតាំងជាក់ស្តែងមួយលើកៗ។ ប្រសិនបើភាគី "ក" ខកខានការរៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា កិច្ចប្រជុំ និងសន្និសីទ បន្ទាប់ពីបានជូនដំណឹងភាគី "ខ" ដូចមានចែងក្នុងប្រការ៦ ខាងលើ នោះភាគី "ក" ត្រូវរងនូវការផាកពិន័យចំនួន ២០% នៃតម្លៃជួលទីតាំងជាក់ស្តែងមួយលើកៗ។

**ប្រការ៨- ករណីប្រធានស័ក្តិ**

ក្នុងករណីប្រធានស័ក្តិ ដូចជាអគ្គិភ័យ ទឹកជំនន់ ជំងឺរាតត្បាត បាតុកម្ម កុបកម្ម សង្គ្រាម និងវិបត្តិភ័យដទៃទៀតឬព្រឹត្តិការណ៍ដែលធ្វើឱ្យ ភាគីណាមួយមិនអាចអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងសាជីវកម្មបាន ភាគីនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីស្វែងរកដំណោះស្រាយ។

**ប្រការ៩- ការបញ្ចប់កិច្ចព្រមព្រៀងសាជីវកម្ម**

ភាគី "ក" អាចពិចារណាលើការលុបកិច្ចព្រមព្រៀងសាជីវកម្ម ប្រសិនបើភាគី "ខ" ស្ថិតក្នុងករណីណាមួយដូចខាងក្រោម÷

១. មិនអាចផ្តល់ទីតាំងជូនភាគី "ក" ចំនួន ៣(បី)ដង ក្នុងអំឡុងពេលនៃសុពលភាពកិច្ចព្រមព្រៀងសាជីវកម្ម

២. មិនអាចបំពេញតាមលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងសាជីវកម្ម

៣. ក្ស័យធន ឬស្ថិតក្នុងស្ថានភាពក្ស័យធនដែលមិនអាចសងបំណុលគេបាន។

**ប្រការ១០- ការដោះស្រាយវិវាទ**

កិច្ចព្រមព្រៀងសាជីវកម្ម នេះត្រូវគ្រប់គ្រងនិងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ជម្លោះណាមួយដែលកើតមានឡើងរវាង ភាគី "ក" និងភាគី "ខ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងសាជីវកម្មនេះ ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈអាជ្ញាកណ្តាលមួយរូប ដែលនឹងត្រូវជ្រើសតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ដោយភាគី "ក" និង ភាគី "ខ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របលើការជ្រើសតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាល នោះត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១១- សោហ៊ុយទាក់ទងរឿងក្តី**

ក្នុងករណីរកឃើញថារឿងក្តី ដែលបានកើតឡើងបណ្តាលមកពីភាគីណាមួយរំលោភលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ភាគីនោះត្រូវទទួលខុសត្រូវចំពោះសោហ៊ុយចំណាយពាក់ព័ន្ធនឹងរឿងក្តីនេះ។

**ប្រការ១២- ការប្រើប្រាស់ឯកសារកិច្ចព្រមព្រៀងសាជីវកម្ម**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "ក" នោះភាគី "ខ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចព្រមព្រៀងសាជីវកម្ម ឬមិនត្រូវបង្ហាញឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចព្រមព្រៀងសាជីវកម្មឱ្យទៅអ្នកដទៃ លើកលែងតែក្នុងករណីប្រើប្រាស់ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងសាជីវកម្ម។

**ប្រការ១៣- ឱសានបាន**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចព្រមព្រៀងសាជីវកម្មឱ្យបានម៉ឺងម៉ាត់។ កិច្ចព្រមព្រៀងសាជីវកម្មនេះធ្វើឡើងជាភាសាខ្មែរចំនួន ៧(ប្រាំពីរ) ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ÷

| | |
|---|---|
| -ភាគី "ក" | ចំនួន ៣ ច្បាប់ |
| -ភាគី "ខ" | ចំនួន ២ ច្បាប់ |
| -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ១ ច្បាប់ |
| -ឯកសារ-កាលប្បវត្តិ | ចំនួន ១ ច្បាប់ |

ថ្ងៃ................... ខែ............ ឆ្នាំ.............. ស័ក ព.ស.............

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ............ ឆ្នាំ............

**ភាគី "ក"** **ភាគី "ខ"**

ឈ្មោះនិងត្រា ក្រសួង/ស្ថាប័ន/សហគ្រាសសាធារណៈ/គ្រឹះស្ថានសាធារណៈរដ្ឋបាល/អង្គភាពសាធារណៈប្រហាក់ប្រហែល/អង្គភាពថវិកា

ឈ្មោះនិងត្រា សណ្ឋាគារ/ម្ចាស់ទីតាំង

**ឧបសម្ព័ន្ធទី ២**

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ១៥១ សហវ.ប្រក.អលសា ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្ម សម្រាប់ មុខចំណាយជួលទីតាំងរៀបចំវគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ និងសិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួលជុលរថយន្ត សម្រាប់រដ្ឋបាលថ្នាក់ជាតិ)

**កិច្ចព្រមព្រៀងសាជីវកម្មស្ដីពីការទិញសំបុត្រយន្តហោះ**

**រវាង**

- **ក្រសួង/ស្ថាប័ន/សហគ្រាសសាធារណៈ/គ្រឹះស្ថានសាធារណៈរដ្ឋបាល/អគ្គនាយកដ្ឋាន/នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ/អង្គភាពថវិកា** .................... តំណាងដោយ .......................... មុខងារ..................... មានអាសយដ្ឋាន ......................... ........................ ហៅកាត់ថាភាគី "**ក**"

**និង**

- **ក្រុមហ៊ុនអាកាសចរណ៍/ការិយាល័យទេសចរណ៍ឬភ្នាក់ងារទេសចរណ៍**..................... តំណាងដោយ.............................. មុខងារ................................ មានអាសយដ្ឋាន ................................................. ហៅកាត់ថាភាគី "**ខ**"។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖**

**ប្រការ១- អំពីគោលការណ៍**

ភាគី "ក" និងភាគី "ខ" យល់ព្រមប្រើប្រាស់និងផ្ដល់សេវាកម្មលើការទិញ-លក់សំបុត្រយន្តហោះ សម្រាប់រយៈពេល ..... ( )ឆ្នាំ ចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ...... ដល់ថ្ងៃទី.....ខែ.....ឆ្នាំ......។

**ប្រការ២- តម្លៃសំបុត្រយន្តហោះ**

សំបុត្រយន្តហោះត្រូវមានតម្លៃទាបសមស្របធៀបជាមួយតម្លៃធម្មតា (តម្លៃមិនមានការចុះកិច្ចព្រមព្រៀងសាជីវកម្ម)។ តម្លៃសំបុត្រយន្តហោះត្រូវប្រែប្រួលតាមលក្ខខណ្ឌជាក់ស្ដែងមានជាអាទិ៍ ៖ ក្រុមហ៊ុនអាកាសចរណ៍ ប្រភេទសំបុត្រ ចំនួនសំបុត្រ ព្រលានយន្តហោះឬគោលដៅហោះហើរ គម្លាតពេលវេលាថ្ងៃទិញសំបុត្រ និងរដូវកាលហោះហើរ។

តម្លៃសំបុត្រយន្តហោះសរុបជាក់ស្ដែងមួយលើកៗ ត្រូវផ្អែកតាមតារាងតម្លៃសំបុត្រយន្តហោះដូចមានចែងក្នុងប្រការ៣ នៃកិច្ចព្រមព្រៀងសាជីវកម្មនេះ និងត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរ។

**ប្រការ៣- ភារកិច្ចរបស់គូភាគី**

ភាគី "ខ" ត្រូវផ្ដល់ជូនភាគី "ក" នូវតារាងតម្លៃសំបុត្រយន្តហោះប្រចាំត្រីមាសនៅរៀងរាល់ដើមត្រីមាសនីមួយៗ។

ភាគី "ក" ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរពីការទិញសំបុត្រយន្តហោះទៅភាគី "ខ" យ៉ាងតិច ១(មួយ) សប្តាហ៍មុនកាលបរិច្ឆេទធ្វើដំណើរម្តងៗដោយបញ្ជាក់អំពី÷ (១)ក្រុមហ៊ុនអាកាសចរណ៍ (២)ប្រភេទនិងចំនួនសំបុត្រ (៣)ព្រលានយន្តហោះឬគោលដៅហោះហើរ (៤)កាលបរិច្ឆេទធ្វើដំណើរ និង (៥)ឯកសារពាក់ព័ន្ធចាំបាច់ផ្សេងទៀត។

ក្នុងករណីភាគី "ក" ជូនដំណឹងអំពីកាលបរិច្ឆេទធ្វើដំណើរ តិចជាងការកំណត់ខាងលើ ហើយភាគី "ខ" អាចផ្គត់ផ្គង់សំបុត្រយន្តហោះបានទាន់ពេលវេលា នោះភាគី "ខ" ត្រូវផ្តល់សំបុត្រយន្តហោះនិងសេវាកម្មពាក់ព័ន្ធតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងសាជីវកម្មនេះ។

ភាគី "ខ" ត្រូវចេញវិក្កយបត្រ (Invoice) ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីតម្លៃសំបុត្រយន្តហោះសរុបដែលភាគី "ក" បានបញ្ជាទិញជាក់ស្តែងម្តងៗ។

**ប្រការ៤- ការកែប្រែកាលបរិច្ឆេទសំបុត្រយន្តហោះ**

ក្នុងករណីភាគី "ក" កែប្រែកាលបរិច្ឆេទនៃការចេញដំណើរ នោះ÷

- ភាគី "ខ" ត្រូវផ្លាស់ប្តូរជូនភាគី "ក" ដោយឥតលក្ខខណ្ឌចំពោះប្រភេទសំបុត្រយន្តហោះដែលអាចកែប្រែបាន (changeable air-ticket)
- ភាគី "ខ" ត្រូវផ្លាស់ប្តូរជូនភាគី "ក" ចំពោះប្រភេទសំបុត្រយន្តហោះដែលមិនអាចកែប្រែបាន (non-changeable air-ticket)។ រាល់ការចំណាយសម្រាប់ការផ្លាស់ប្តូរនេះជាបន្ទុករបស់ភាគី "ក"។

**ប្រការ៥- ការផ្លាស់ប្តូរជើងហោះហើរ និងការសងប្រាក់វិញ**

ក្នុងករណីមានការផ្លាស់ប្តូរជើងហោះហើរខុសពីគោលដៅដើមដោយភាគី "ក" នោះតម្លៃសំបុត្រយន្តហោះអាចប្រែប្រួលទៅតាមការជាក់ស្តែង។ ប្រសិនបើមានការលុបជើងហោះហើរដោយក្រុមហ៊ុនអាកាសចរណ៍ពាក់ព័ន្ធភាគី "ខ" ត្រូវសងប្រាក់ថ្លៃសំបុត្រយន្តហោះគ្រប់ចំនួនជូនភាគី "ក" វិញ។

ក្នុងករណីមានការពន្យារពេលនៃការហោះហើរបណ្តាលឱ្យភាគី "ក" មិនបានប្រើប្រាស់នូវផ្នែកខ្លះនៃសំបុត្រយន្តហោះ ភាគី "ខ" ត្រូវសងប្រាក់ថ្លៃសំបុត្រយន្តហោះដែលមិនបានប្រើប្រាស់នោះជូនភាគី "ក" វិញ។

**ប្រការ៦- សេវាកម្មពាក់ព័ន្ធផ្សេងៗបន្ថែម**

ភាគី "ខ" ត្រូវផ្តល់សេវាកម្មបន្ថែមលើការជួយកក់សណ្ឋាគារ ជួលរថយន្ត តាមសំណើពីភាគី "ក" ក្នុងតម្លៃទាបសមស្រប។ បន្ថែមពីលើនេះភាគី "ខ" ត្រូវជួយផ្តល់ព័ត៌មានពីការផ្លាស់ប្តូរ និងបច្ចុប្បន្នភាពព័ត៌មានលើសំបុត្រយន្តហោះដោយឥតគិតថ្លៃទៅឱ្យភាគី "ក"។

**ប្រការ៧- ការទូទាត់**

ភាគី "ខ" ត្រូវបូកសរុបប្រចាំខែនូវតម្លៃសំបុត្រយន្តហោះដែលភាគី "ក" បានទិញ ដើម្បីរៀបចំវិក្កយបត្ររួចផ្ញើមកភាគី "ក" ដើម្បីធ្វើការទូទាត់។ ការទូទាត់ត្រូវធ្វើឡើងមិនឱ្យលើស ៣០(សាមសិប)ថ្ងៃ ក្រោយកាលបរិច្ឆេទទទួលវិក្កយបត្រ ដោយត្រូវបង្វែរចូលគណនីរបស់ក្រុមហ៊ុនអាកាសចរណ៍/ការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍។

**ប្រការ៨- ពន្ធ អាករ**

ភាគី "ខ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធអាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៩- ការកែប្រែបញ្ជាទិញ**

ប្រសិនបើភាគី"ក" មានតម្រូវការចាំបាច់ក្នុងការផ្លាស់ប្តូរការបញ្ជាទិញ នោះភាគី "ក" ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគី "ខ" ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃ មុនកាលបរិច្ឆេទធ្វើដំណើរជាក់ស្តែងមួយលើកៗ និងត្រូវពិភាក្សាស្វែងរកដំណោះស្រាយលើការកែប្រែនោះ។

**ប្រការ១០- ការផាកពិន័យ**

ក្នុងករណីមិនបានបំពេញកាតព្វកិច្ចក្នុងការផ្គត់ផ្គង់សំបុត្រយន្តហោះ បានតាមកាលបរិច្ឆេទកំណត់ ដែលបណ្តាលមកពីភាគី "ខ" នោះភាគី "ខ" ត្រូវទទួលរងនូវការផាកពិន័យចំនួន ២០% នៃតម្លៃសំបុត្រយន្តហោះជាក់ស្តែងមួយលើកៗ។ ប្រសិនបើភាគី "ក" លុបការធ្វើដំណើរបន្ទាប់ពីបានជូនដំណឹងភាគី "ខ" ដូចមានចែងក្នុងប្រការ៦ ខាងលើ នោះភាគី "ក" ត្រូវរងនូវការផាកពិន័យចំនួន ២០% នៃតម្លៃសំបុត្រយន្តហោះជាក់ស្តែងមួយលើកៗ។

**ប្រការ១១- ករណីប្រធានស័ក្តិ**

ក្នុងករណីប្រធានស័ក្តិ ដូចជាអគ្គិភ័យ ទឹកជំនន់ ជំងឺរាតត្បាត បាតុកម្ម កុបកម្ម សង្គ្រាម និងវិបត្តិភ័យដទៃទៀតឬព្រឹត្តិការណ៍ដែលធ្វើឱ្យ ភាគីណាមួយមិនអាចអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងសាជីវកម្មបាន ភាគីនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីស្វែងរកដំណោះស្រាយ។

**ប្រការ១២- ការបញ្ចប់កិច្ចព្រមព្រៀងសាជីវកម្ម**

ភាគី "ក" អាចពិចារណាលើការលុបកិច្ចព្រមព្រៀងសាជីវកម្ម ប្រសិនបើភាគី "ខ" ស្ថិតក្នុងករណីណាមួយដូចខាងក្រោម÷

១.មិនអាចផ្តល់សំបុត្រយន្តហោះជូនភាគី "ក" ចំនួន ៣(បី)ដង ក្នុងអំឡុងពេលនៃសុពលភាពកិច្ចព្រមព្រៀងសាជីវកម្ម

២. មិនអាចបំពេញតាមលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងសាជីវកម្ម

៣. ក្ស័យធន ឬស្ថិតក្នុងស្ថានភាពក្ស័យធនដែលមិនអាចសងបំណុលគេបាន។

**ប្រការ១៣- ការដោះស្រាយវិវាទ**

កិច្ចព្រមព្រៀងសាជីវកម្ម នេះត្រូវគ្រប់គ្រងនិងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ជម្លោះណាមួយដែលកើតមានឡើងរវាង ភាគី "ក" និងភាគី "ខ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងសាជីវកម្មនេះ ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈអាជ្ញាកណ្តាលមួយរូប ដែលនឹងត្រូវជ្រើសតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ដោយភាគី "ក" និង ភាគី "ខ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របលើការជ្រើសតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាល នោះត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៤- សោហ៊ុយទាក់ទងរឿងក្តី**

ក្នុងករណីរកឃើញថារឿងក្តី ដែលបានកើតឡើងបណ្តាលមកពីភាគីណាមួយរំលោភលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ភាគីនោះត្រូវទទួលខុសត្រូវចំពោះសោហ៊ុយចំណាយពាក់ព័ន្ធនឹងរឿងក្តីនេះ។

**ប្រការ១៥- ការប្រើប្រាស់ឯកសារកិច្ចព្រមព្រៀងសាជីវកម្ម**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "ក" នោះភាគី "ខ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចព្រមព្រៀងសាជីវកម្ម ឬមិនត្រូវបង្ហាញឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចព្រមព្រៀងសាជីវកម្មឱ្យទៅអ្នកដទៃ លើកលែងតែក្នុងករណីប្រើប្រាស់ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងសាជីវកម្ម ។

**ប្រការ១៦- ឱសានវាទ**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចព្រមព្រៀងសាជីវកម្មឱ្យបានម៉ឺងម៉ាត់។ កិច្ចព្រមព្រៀងសាជីវកម្មនេះធ្វើឡើងជាភាសាខ្មែរចំនួន ៧(ប្រាំពីរ) ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ÷

| | |
|---|---|
| -ភាគី "ក" | ចំនួន ៣ ច្បាប់ |
| -ភាគី "ខ" | ចំនួន ២ ច្បាប់ |
| -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ១ ច្បាប់ |
| -ឯកសារ- កាលប្បវត្តិ | ចំនួន ១ ច្បាប់ |

ថ្ងៃ.................... ខែ............. ឆ្នាំ.............. ស័ក ព.ស.............

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ............ ឆ្នាំ............

**ភាគី "ក"** **ភាគី "ខ"**

ឈ្មោះនិងត្រា ក្រសួង/ ស្ថាប័ន/ សហគ្រាសសាធារណៈ/ គ្រឹះស្ថានសាធារណៈរដ្ឋបាល/អង្គភាពសាធារណៈប្រហាក់ប្រហែល/អង្គភាពថវិកា

ឈ្មោះនិងត្រា ក្រុមហ៊ុនអាកាសចរណ៍/ការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍

## ឧបសម្ព័ន្ធទី ៣

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ១៥១ សហវ.ប្រក.អលសា ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងសាជីវកម្ម សម្រាប់ មុខចំណាយជួលទីតាំងរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងសិក្ខាសាលា និងសន្និសីទ ចំណាយទិញសំបុត្រយន្តហោះ និងចំណាយជួសជុលរថយន្ត សម្រាប់រដ្ឋបាលថ្នាក់ជាតិ)

## កិច្ចព្រមព្រៀងសាជីវកម្មស្តីពីការជួសជុលរថយន្ត

**រវាង**

- **ក្រសួង/ស្ថាប័ន/សហគ្រាសសាធារណៈ/គ្រឹះស្ថានសាធារណៈរដ្ឋបាល/អង្គភាពសាធារណៈប្រហាក់ប្រហែល/អង្គភាពថវិកា** .................... តំណាងដោយ ........................... មុខងារ..................... មានអាសយដ្ឋាន ......................... ........................ ហៅកាត់ថាភាគី “**ក**”

**និង**

- **ក្រុមហ៊ុន/យានដ្ឋានជួសជុលរថយន្ត**.............. តំណាងដោយ .......................... មុខងារ..................... មានអាសយដ្ឋាន ................................................. ហៅកាត់ថាភាគី “**ខ**”។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ÷**

**ប្រការ១- អំពីគោលការណ៍**

ភាគី “ក” និងភាគី “ខ” យល់ព្រមប្រើប្រាស់និងផ្តល់សេវាកម្មលើការជួសជុលរថយន្តសម្រាប់រយៈពេល ពេល..... ( )ឆ្នាំ ចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ......ដល់ថ្ងៃទី.....ខែ.....ឆ្នាំ......។

**ប្រការ២- តម្លៃជួសជុលរថយន្ត**

តម្លៃជួសជុលរថយន្ត (ថ្លៃឈ្នួលពលកម្ម និងថ្លៃគ្រឿងបន្លាស់) ត្រូវមានតម្លៃទាបសមស្របធៀបជាមួយតម្លៃធម្មតា (តម្លៃមិនមានការចុះកិច្ចព្រមព្រៀងសាជីវកម្ម)។

តម្លៃជួសជុលរថយន្តសរុបជាក់ស្តែងមួយលើកៗ ត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរ។

**ប្រការ៣- ភារកិច្ចរបស់គូភាគី**

-ភាគី “ក” ត្រូវបញ្ជាក់ជូនភាគី “ខ” អំពីមូលហេតុបឋមនៃតម្រូវការជួសជុលរថយន្ត និងពេលវេលានៃតម្រូវការប្រើប្រាស់រថយន្ត

-ភាគី “ខ” ត្រូវពិនិត្យឱ្យបានហ្មត់ចត់អំពីស្ថានភាពនិងទំហំខូចខាតរបស់រថយន្ត រួចធ្វើការវាយតម្លៃបឋមអំពីទំហំនៃការខូចខាតរថយន្ត និងថ្លៃជួសជុលដោយបញ្ជាក់អំពីថ្លៃឈ្នួលពលកម្ម និងថ្លៃគ្រឿងបន្លាស់ជូនភាគី “ក”

-ភាគី “ក” ត្រូវធ្វើការសម្រេចអនុញ្ញាតឱ្យភាគី “ខ” ជួសជុលរថយន្តផ្នែកណាមួយ ឬទាំងស្រុង តាមការវាយតម្លៃបឋមពីភាគី “ខ”

-ភាគី “ខ” ត្រូវចេញវិក្កយបត្របណ្តោះអាសន្នជូនភាគី “ក” បន្ទាប់ពីភាគី “ក” បានធ្វើការសម្រេចចិត្តឱ្យជួសជុល

-ភាគី “ក” រក្សាទុកវិក្កយបត្របណ្តោះអាសន្ននោះ សម្រាប់ផ្ទៀងផ្ទាត់ជាមួយវិក្កយបត្រជួសជុលជាក់ស្តែងនៅពេលប្រគល់ ទទួលរថយន្តជួសជុលរួចរាល់

-ភាគី “ខ” ត្រូវជួសជុលសង ឬប្តូរសងគ្រឿងបន្លាស់ ឬសងរថយន្ត ដែលខូចខាត ឬបាត់បង់ដោយសារការធ្វេសប្រហែសរបស់ខ្លួនក្នុងអំឡុងពេលនៃការជួសជុលរថយន្ត

-ភាគី “ខ” ត្រូវជួសជុលរថយន្តឱ្យបានរួចរាល់តាមពេលវេលាដែលបានព្រមព្រៀងគ្នាដោយមិនអាចពន្យារពេលបានឡើយ។

**ប្រការ៤- ការធានាគុណភាពការជួសជុលរថយន្ត**

ភាគី “ខ” ត្រូវធានាគុណភាពលើការជួសជុលរថយន្តក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីថ្ងៃប្រគល់ ទទួលរថយន្តជួសជុលរួចរាល់។ ក្នុងអំឡុងពេលធានាគុណភាព ករណីពិនិត្យឃើញថារថយន្តមានដំណើរការមិនប្រក្រតីពាក់ព័ន្ធនឹងការជួសជុលនេះ ភាគី “ខ” ត្រូវរួសរាន់ជួសជុលឡើងវិញ ដោយការចំណាយគឺជាបន្ទុករបស់ភាគី “ខ” ទាំងស្រុង។

**ប្រការ៥- ការចុះកិច្ចព្រមព្រៀងសាជីវកម្មបន្ត**

ភាគី “ខ” មិនត្រូវបានអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងសាជីវកម្មបន្តនូវផ្នែកខ្លះ ឬទាំងមូលទៅឱ្យភាគីទី៣ បានឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីភាគី “ក”។ ក្នុងករណីមានការយល់ព្រមពីភាគី “ក” នោះភាគី “ខ” ត្រូវទទួលខុសត្រូវលើគុណភាពនៃការជួសជុល និងមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមថ្លៃជួសជុលទេ។

**ប្រការ៦- អំពីការទូទាត់**

ភាគី “ខ” ត្រូវបូកសរុបប្រចាំខែនូវថ្លៃជួសជុលរថយន្ត ដើម្បីរៀបចំវិក្កយបត្ររួចផ្ញើមកភាគី “ក” ដើម្បីធ្វើការទូទាត់។ ការទូទាត់ត្រូវធ្វើឡើងមិនឱ្យលើស ៣០(សាមសិប)ថ្ងៃ ក្រោយកាលបរិច្ឆេទទទួលវិក្កយបត្រ ដោយត្រូវបង្វែរចូលគណនីរបស់ក្រុមហ៊ុន/ យានដ្ឋានជួសជុលរថយន្ត។

**ប្រការ៧- ពន្ធ អាករ**

ភាគី “ខ” មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធអាករគ្រប់ប្រភេទ រួមទាំង “អាករលើតម្លៃបន្ថែម” តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៨- ការកែប្រែលើការជួសជុល**

ក្នុងករណីភាគី“ក” មានតម្រូវការចាំបាច់ក្នុងការផ្លាស់ប្តូរលើការជួសជុល នោះភាគី“ក” ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគី “ខ” និងត្រូវពិភាក្សាស្វែងរកដំណោះស្រាយអំពីការផ្លាស់ប្តូរការជួសជុលនោះ។

**ប្រការ៩- ការផាកពិន័យ**

ក្នុងករណីភាគី "ខ" មិនបានធ្វើការជួសជុលរថយន្ត បានទាន់ពេលវេលាតាមកាលបរិច្ឆេទកំណត់ ដែលបណ្តាលមកពីភាគី "ខ" នោះភាគី "ខ" ត្រូវទទួលរងនូវការផាកពិពិន័យក្នុងមួយថ្ងៃចំនួន ៥% នៃថ្លៃជួសជុលរថយន្តជាក់ស្តែងមួយលើកៗ។ ប្រសិនបើភាគី "ក" លុបការជួសជុលរថយន្ត បន្ទាប់ពីបានជូនដំណឹងភាគី "ខ" អំពីការសម្រេចចិត្តឱ្យជួសជុល ដូចមានចែងក្នុងប្រការ៣ ខាងលើ នោះភាគី "ក" ត្រូវរងនូវការផាកពិន័យចំនួន ៥% នៃថ្លៃជួសជុលរថយន្តបឋម។

**ប្រការ១០- ករណីប្រធានស័ក្តិ**

ក្នុងករណីប្រធានស័ក្តិ ដូចជាអគ្គិភ័យ ទឹកជំនន់ ជំងឺរាតត្បាត បាតុកម្ម កុបកម្ម សង្គ្រាម និងវិបត្តិភ័យដទៃទៀតឬព្រឹត្តិការណ៍ដែលធ្វើឱ្យ ភាគីណាមួយមិនអាចអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងសាជីវកម្មបាន ភាគីនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីស្វែងរកដំណោះស្រាយ។

**ប្រការ១១- ការបញ្ចប់កិច្ចព្រមព្រៀងសាជីវកម្ម**

ភាគី "ក" អាចពិចារណាលើការលុបកិច្ចព្រមព្រៀងសាជីវកម្ម ប្រសិនបើភាគី "ខ" ស្ថិតក្នុងករណីណាមួយដូចខាងក្រោម÷

១. មិនទទួលជួសជុលរថយន្តជូនភាគី "ក" ចំនួន ៣(បី)ដង ក្នុងអំឡុងពេលនៃសុពលភាពកិច្ចព្រមព្រៀងសាជីវកម្ម
២. គុណភាពនៃការជួសជុលរថយន្តមិនបានល្អជូនភាគី "ក" ចំនួន ៣(បី)ដង ដូចមានចែងក្នុងប្រការ៤
៣. មិនអាចបំពេញតាមលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងសាជីវកម្ម
៤. ក្ស័យធន ឬស្ថិតក្នុងស្ថានភាពក្ស័យធនដែលមិនអាចសងបំណុលគេបាន។

**ប្រការ១២- ការដោះស្រាយវិវាទ**

កិច្ចព្រមព្រៀងសាជីវកម្ម នេះត្រូវគ្រប់គ្រងនិងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ជម្លោះណាមួយដែលកើតមានឡើងរវាង ភាគី "ក" និងភាគី "ខ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងសាជីវកម្មនេះ ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈអាជ្ញាកណ្តាលមួយរូប ដែលនឹងត្រូវជ្រើសតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ដោយភាគី "ក" និង ភាគី "ខ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របលើការជ្រើសតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាល នោះត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៣- សោហ៊ុយឆាក់ទងរឿងក្តី**

ក្នុងករណីរកឃើញថារឿងក្តី ដែលបានកើតឡើងបណ្តាលមកពីភាគីណាមួយរំលោភលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ភាគីនោះត្រូវទទួលខុសត្រូវចំពោះសោហ៊ុយចំណាយពាក់ព័ន្ធនឹងរឿងក្តីនេះ។

**ប្រការ១៤- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "ក" នោះភាគី "ខ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចព្រមព្រៀងសាជីវកម្ម ឬមិនត្រូវបង្ហាញឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចព្រមព្រៀងសាជីវកម្មឱ្យទៅអ្នកដទៃ លើកលែងតែក្នុងករណីប្រើប្រាស់ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងសាជីវកម្ម។

**ប្រការ១៥- ខ្លឹមសារនិងភាសា**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចព្រមព្រៀងសាជីវកម្មឱ្យបានម៉ឺងម៉ាត់។ កិច្ចព្រមព្រៀងសាជីវកម្មនេះធ្វើឡើងជាភាសាខ្មែរចំនួន ៧(ប្រាំពីរ) ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ÷

| | |
|---|---|
| -ភាគី "ក" | ចំនួន ៣ ច្បាប់ |
| -ភាគី "ខ" | ចំនួន ២ ច្បាប់ |
| -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ១ ច្បាប់ |
| -ឯកសារ- កាលប្បវត្តិ | ចំនួន ១ ច្បាប់ |

ថ្ងៃ.................. ខែ............ ឆ្នាំ................ ស័ក ព.ស.............

.................... ថ្ងៃទី........... ខែ............ ឆ្នាំ............

**ភាគី "ក"** **ភាគី "ខ"**

ឈ្មោះនិងត្រា ក្រសួង/ ស្ថាប័ន/ សហគ្រាសសាធារណៈ/ គ្រឹះស្ថានសាធារណៈរដ្ឋបាល/អង្គភាពសាធារណៈប្រហាក់ប្រហែល/អង្គភាពថវិកា

ឈ្មោះនិងត្រា ក្រុមហ៊ុន/ យានដ្ឋានជួសជុលរថយន្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៣ សហវ.

## សារាចរ
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី៣

អនុវត្តតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមក្នុងការបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងបានដាក់ឱ្យអនុវត្តជាផ្លូវការនៅរដ្ឋបាលកណ្តាលចំនួន ២៣ (ម្ភៃបី) ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញចំនួន ១៨ (ដប់ប្រាំបី) នៅរាជធានី ខេត្តទាំង ២៥ (ម្ភៃប្រាំ) និងបានពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធ NRMIS ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត)។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តផ្តួចផ្តើមក្នុងការបង្កើតប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) ផ្សារភ្ជាប់នឹងប្រព័ន្ធ NRMIS ដើម្បីផ្តល់ជាជម្រើសបន្ថែមដល់សាធារណជនក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ដែលនឹងដាក់ឱ្យអនុវត្តជាជំហានៗ។

នៅក្នុងជំហានទី១ និងទី២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងដាក់ឱ្យអនុវត្តការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធ e-Payment សម្រាប់ក្រសួង ចំនួន ១៣ (ដប់បី) រួមទាំងមន្ទីរជំនាញរាជធានី ខេត្ត ក្រោមឱវាទនៅទូទាំងប្រទេសរួចរាល់ហើយ។ ដោយឡែក នៅក្នុងជំហានទី៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធ e-Payment នេះ ទៅដល់ក្រសួង ស្ថាប័ន ចំនួន ១០ (ដប់) បន្ថែមទៀត គឺ ១.ក្រសួងព្រះបរមរាជវាំង, ២.រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ៣.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ៤.ក្រសួងការពារជាតិ, ៥.ក្រសួងមហាផ្ទៃ, ៦.ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ៧.ក្រសួងព័ត៌មាន, ៨.ក្រសួងសុខាភិបាល, ៩.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ១០.ក្រសួងយុត្តិធម៌ (ផ្នែកយុត្តិធម៌, តុលាការកំពូល, សាលាឧទ្ធរណ៍ និងសាលាដំបូងរាជធានី ខេត្ត) រួមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទនៅទូទាំងប្រទេស។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធ e-Payment សម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធ ជាមួយនឹងក្រសួង ស្ថាប័ន រួមទាំងមន្ទីរ អង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងជំហានបន្តបន្ទាប់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ដែលអនុវត្តប្រព័ន្ធ e-Payment ជំហានទី៣ ដូចតទៅ÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

១. ក្រសួង ស្ថាប័នទាំង ១០ (ដប់) ខាងលើ ត្រូវបើកគណនីចរន្តចំនួន ០១ (មួយ) ជាប្រាក់រៀល ឬ ០២ (ពីរ) ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ជាមួយនឹងធនាគារពាណិជ្ជដៃគូ (ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ធនាគារ កាណាឌីយ៉ា ក.អ) តាមស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង ស្ថាប័ន សាមី (ប្រមូលជាប្រាក់រៀល ឬ ប្រាក់ដុល្លារអាមេរិក) ដើម្បីទទួលសាច់ប្រាក់ដែលជាចំណែកប្រាក់រង្វាន់ពីការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញសាមីប្រមូលបាន។ រាល់ការបើកគណនីចរន្តទាំងនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិដោយមានការស្នើសុំរបស់ក្រសួង ស្ថាប័ន សាមី។

២. ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញ ត្រូវបោះពុម្ពវិក្កយបត្រដែលមានកូដឃ្យូអរ (QR Code) ចេញពីប្រព័ន្ធ NRMIS ប្រគល់ជូនអតិថិជនដែលបង់ចំណូលមិនមែនសារពើពន្ធជូនក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញ ដោយអតិថិជនអាចជ្រើសរើសវិធីទូទាត់តាមប្រព័ន្ធ e-Payment ដោយប្រើប្រាស់កម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (NRMIS App) ឬ កម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ធនាគារពាណិជ្ជដៃគូ។

៣. ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញ ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធ ដើម្បីផ្សព្វផ្សាយអំពីជម្រើសក្នុងការបង់ចំណូលមិនមែនសារពើពន្ធដោយការប្រើប្រាស់ប្រព័ន្ធ e-Payment។

៤. សម្រាប់ការបង់ចំណូលពីសេវាសាធារណៈមានទំហំទឹកប្រាក់ចាប់ពី ១ ០០០ ០០០ (មួយលាន) រៀល ឡើងទៅ ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញ ឬ អតិថិជនត្រូវបានលើកទឹកចិត្តឱ្យអនុវត្តការបង់ចំណូលតាមប្រព័ន្ធ e-Payment។ ដោយឡែក ចំពោះចំណូលពីសេវាសាធារណៈមានទំហំទឹកប្រាក់ក្រោម ១ ០០០ ០០០ (មួយលាន) រៀល អាចប្រមូលនិងបង់ជាមួយរជ្ជទេយ្យករចំណូល។

៥. ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត អាចអនុវត្តការបង់ចំណូលតាមប្រព័ន្ធ e-Payment ដោយមិនកំណត់ទំហំទឹកប្រាក់។

៦. ចំពោះចំណូលដែលទទួលបានតាមប្រព័ន្ធ e-Payment នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សំរាក ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញត្រូវកំណត់យកកាលបរិច្ឆេទបញ្ចប់វិក្កយបត្រនៅថ្ងៃដំបូងនៃថ្ងៃចូលធ្វើការធម្មតា។ ចំពោះ រូបិយបណ្ណជាដុល្លារអាមេរិក ការកត់ត្រាចំណូលត្រូវកំណត់យកអត្រាប្តូរប្រាក់តាមថ្ងៃដំបូងនៃថ្ងៃចូលធ្វើការធម្មតា។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ខាងលើ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ទីរជំនាញរាជធានី ខេត្ត ក្រោមឱវាទ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

